## សមាគមឧកញ៉ាកម្ពុជា

# ព្រឹត្តិបត្រព័ត៌មានសមាគមឧកញ៉ាកម្ពុជា

## ឆ្នាំទី២ លេខ៧ ត្រីមាសទី៣ ឆ្នាំ២០២៥



ផលិតដោយៈ អគ្គលេខាធិការដ្ឋាន
សមាគមឧកញ៉ាកម្ពុជា

# មាតិកា


- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ាប្រធានដឹកនាំសមាជិកសមាគមឧកញ៉ាកម្ពុជាចំនួន ១០រូបចូលរួម សិក្ខាសាលាស្តីពី «ភាពជាដៃគូរវាងរដ្ឋឯកជន និងពលរដ្ឋ ដើម្បីកម្ពុជាប្រកបដោយជំនាញ»....................១
- អគារសិក្សា ៥ខ្នង សរុប ៥៥បន្ទប់ជាអំណោយរបស់សមាគមឧកញ៉ាកម្ពុជា ជូនសាលាចំនួន ៥នៅក្នុងខេត្តកំពង់ធំ ត្រូវបានប្រារព្ធពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់ជាផ្លូវការ....................................................................................៣
- អ្នកឧកញ៉ា គួន ធីតា ដឹកនាំសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីផ្សព្វផ្សាយ «របាយការណ៍វឌ្ឍនភាព នៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ ប្រចាំឆមាសទី២ ឆ្នាំ២០២៤ និងពិធីអបអរសាទរខួបគម្រប់ ២៥ឆ្នាំ នៃកិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងផ្នែកឯកជន» ..........................៦
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំសមាជិកសមាគមឧកញ៉ាកម្ពុជាចូលរួម «ពិព័រណ៍អាពាហ៍ពិពាហ៍លើកទី២ ប្រចាំឆ្នាំ២០២៥» ក្រោមអធិបតីភាព **លោកជំទាវបណ្ឌិត ពេជ ចន្ទមុនី ហ៊ុន ម៉ាណែត** ....................................៨
- សមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួម «សន្និសីទស្តីពីការបង្កើតកិច្ចសហការរួមគ្នាកម្ពុជា–ជប៉ុន លើកទី៣ ឆ្ពោះទៅកាន់ការបង្កើតប្រព័ន្ធអេកូឡូស៊ី និងនវានុវត្តន៍ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថលបៃតង និងលំហអាកាសមកពីប្រទេសជប៉ុន». ៩
- សមាជិកនៃសមាគមឧកញ៉ាកម្ពុជាចូលរួម «វេទិកាជំរុញផ្សព្វផ្សាយសួនឧស្សាហកម្មកម្ពុជា-ចិន» ក្រោមអធិបតីភាពលោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ..............................................................................................១១
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តមឧត្តមសេនីយ៍ឯក ដួង សំនៀង ដែលបានពលីក្នុងសមរភូមិនាខេត្តព្រះវិហារ...១៣
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ លោកអនុសេនីយ៍ឯក ពោ វ៉ៃ ដែលបានពលីក្នុងសមរភូមិ......................................១៤
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ លោកព្រឹន្ទបាលទោ រិន វាសនា ដែលបានពលីក្នុងសមរភូមិមុំបី.............................១៥
- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បន្តចូលរួមគោរពវិញ្ញាណក្ខន្ធ លោកនាយចំណង់ ម៉ៅ ស៊ា ដែលបានពលីក្នុងសមរភូមិតំបន់ភ្នំទ្រព្យ..........................................................................................................................១៦
- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បន្តចូលរួមគោរពវិញ្ញាណក្ខន្ធ លោកព្រឹន្ទបាលឯក ណៃ ចន្ទី ដែលបានពលីក្នុងសមរភូមិដើម្បីការពារបូរណភាពទឹកដី..................................................................................................................១៧
- អ្នកឧកញ៉ា តុល លន សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ លោកអនុសេនីយ៍ទោ តែម សុខជា ដែលបានពលីក្នុងសមរភូមិខេត្តព្រះវិហារ១១៨
- អ្នកឧកញ៉ា តុល លន សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ បន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ លោកអនុសេនីយ៍ត្រី សំរឹត ព្រី នៅខេត្តព្រៃវែង..............................១៩
- អ្នកឧកញ៉ា អ៊ាន អេឡែន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ លោកព្រឹន្ទបាលទោ ស៊ឹម គា នាខេត្តព្រះវិហារ..........................................២០

- អ្នកឧកញ៉ា អ៊ាន អេឡៃន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ បន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ លោកអនុសេនីយ៍ត្រី ច័ន្ទ តារា ដែលបានពលីក្នុងសមរភូមិភ្នំទ្រព្យ........................២១
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ លោកព្រឹន្ទបាលឯកឱ សេង នៅស្រុកបារាយណ៍ ខេត្តកំពង់ធំ..............................២២
- អ្នកឧកញ៉ា អ៊ាន អេឡៃន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធវីរកងទ័ពពលីចំនួន ៤រូបនៅវត្តប្រាសាទរាជាសំរោង ខេត្តឧត្តរមានជ័យ....................២៣
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ត្រី ញាត ឈីន នៅស្រុកសណ្ដាន់ ខេត្តកំពង់ធំ..........................២៤
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធលោកព្រឹន្ទបាលឯក ពេជ្រ ង៉ោល នៅស្រុកសណ្ដាន់ ខេត្តកំពង់ធំ..........................២៥
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធលោកវរសេនីយ៍ត្រី ជួង លៀប ដែលបានពលីនៅសមរភូមិប្រាសាទតាមាន់ធំ............២៦
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធលោកព្រឹន្ទបាលឯក ថា សុភា នៅស្រុកសូត្រនិគម ខេត្តសៀមរាប.........................២៧
- ឧកញ៉ា នង សុវណ្ណរ័ត្ន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធលោកពលបាលឯក ឈូក វ៉ាន់ត្រួយ នៅស្រុកអង្គរជ័យ ខេត្តកំពត..................................................២៨
- ឧកញ៉ា នង សុវណ្ណរ័ត្ន សមាជិកសកម្ម និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ បន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ត្រី ចាន់ រដ្ឋ នៅស្រុកដំណាក់ចង្អើ ខេត្តកែប...............................២៩
- អ្នកឧកញ៉ា គួន ធីតា សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធលោកវរសេនីយ៍ត្រី អ៊ួន ហាច នៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង..........៣០
- អ្នកឧកញ៉ា ប៊ុន ហៃ សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធវីរកងទ័ពពលីចំនួន ៥ រូបនៅខេត្តសៀមរាប.................................................៣១
- លោកអ្នកឧកញ៉ា លាង យុន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធវីរកងទ័ពពលីចំនួន ៤ រូបនៅខេត្តសៀមរាប.......................................................៣៣
- លោកអ្នកឧកញ៉ា លាង យុន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធវីរកងទ័ពពលីចំនួន ៣ រូបនៅខេត្តបាត់ដំបង.....................................................៣៥
- អ្នកឧកញ៉ា សំ សុខនឿន និងឧកញ៉ា លី រិទ្ធ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ចូលរួមគោរពវិញ្ញាណក្ខន្ធវីរកងទ័ពពលីចំនួន ៥រូបនៅខេត្តកំពង់ចាម ត្បូងឃ្មុំ និងស្ទឹងត្រែង.............................................................................៣៧
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ (ក.ផ.ផ.) លើកទី៦ ក្រោមអធិបតីភាពឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍......................................................៣៩
- អ្នកឧកញ៉ា សៀ ឬទ្ធី ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមជំនួបពិភាក្សាការងារអំពីការរៀបចំដំណើរបេសកកម្មទាក់ទាញ និងវិនិយោគនៅប្រទេសអូស្ត្រាលី ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល................៤០

- អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិនិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលា........................................................................................៤២
- អ្នកឧកញ៉ា គួន ធីតា ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ និងគ្លីនិក Jeremiah's Hope Clinic....................................................................................................................................................៤៤
- អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប....................................................................................៤៦
- អ្នកឧកញ៉ា ហ៊ុន ឡាក់ បន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យភូមិភាគ៤ ក្នុងខេត្តសៀមរាប..........................................................................៤៨
- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បន្តចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិនិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តមិត្តភាពកម្ពុជា-ជប៉ុន មង្គលបូរី ក្នុងខេត្តបន្ទាយមានជ័យ...................................................................៥០
- អ្នកឧកញ៉ា ផៃ ហុកឈួន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកងពលថ្មើជើងលេខ៤២ ក្នុងខេត្តឧត្តរមានជ័យ.............................................៥២
- អ្នកឧកញ៉ា អ៊ាន អេឡែន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅគិលានដ្ឋានតំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ.......................................................៥៤
- អ្នកឧកញ៉ា ទី គឹមស្រ៊ាន ដឹកនាំគណៈប្រតិភូឱសមាគមឧកញ៉ាកម្ពុជាចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិនិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត....................................................................................................៥៦
- អ្នកឧកញ៉ា អ៊ាន អេឡែន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធសពយុទ្ធជនពលី លោកអនុសេនីយ៍ឯក ញឹក ប៊ុនសោន នៅខេត្តស្វាយរៀង..............................................................................................៥៨
- អ្នកឧកញ៉ា ផៃ ហុកឈួន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចុះសួរសុខទុក្ខ និងនាំយកអំណោយជាថវិកាប្រគល់ជូនវីរយុទ្ធជនដែលរបួសនិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យចំនួន ២ក្នុងខេត្តព្រះវិហារ.........................................៥៩
- អ្នកឧកញ៉ា ផៃ ហុកឈួន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធសពវីរយុទ្ធជនដែលបានពលីក្នុងសមរភូមិចំនួន ២រូបក្នុងខេត្តព្រះវិហារ..........................................................................................................៦៣
- អ្នកឧកញ៉ា ផៃ ហុកឈួន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធសពលោកវរសេនីយ៍ត្រី ប៊ូ ផូស្ថិតនៅខេត្តកំពង់ធំ.....................................................................................................................................៦៤
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ រួមជាមួយសមាជិកសមាគមឧកញ៉ាកម្ពុជាចូលរួមជំនួបពិភាក្សាជាមួយលោក គី សុខគីម នាយកប្រតិបត្តិមូលនិធិអភិវឌ្ឍន៍ជំនាញ ....................................................................................៦៥
- អ្នកឧកញ៉ា ឡាវ កាង ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចុះសួរសុខទុក្ខនិងប្រគល់អំណោយជាម៉ូតូ កង្ហារ ជូនមន្ទីរពេទ្យកងពលថ្មើជើងលេខ៤២ក្នុងខេត្តឧត្តរមានជ័យ និងថវិកាជូនបុគ្គលិកសុខាភិបាលនៅទីនោះផងដែរ............៦៧
- អ្នកឧកញ៉ា ឡាវ កាង ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចុះសួរសុខទុក្ខ និងនាំយកអំណោយ ជាថវិកាជូនវីរកងទ័ពដែលបានរបួសក្នុងសមរភូមិនិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ.................................៦៩
- អ្នកឧកញ៉ា សៀ ឫទ្ធី ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រីអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគនៅប្រទេសអូស្ត្រាលី...............៧១

- អ្នកឧកញ៉ា ហេង ឡុង អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធវីរកងទ័ព ព្រៀប ចំរើន នៅខេត្តត្បូងឃ្មុំ........................................................................៨២
- អ្នកឧកញ៉ា ហេង ឡុង ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធសពលោកអនុសេនីយ៍ទោ ហេង តាំង នៅខេត្តកំពង់ចាម........................................................................................................៨៣
- ឧកញ៉ាបណ្ឌិត លីរិទ្ធ សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីបើកសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការសាលាអន្តរជាតិប្រូមស៍ហ្គ្រូវកម្ពុជា.........................៨៤
- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុលឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មទាក់ទាញនិងជំរុញវិនិយោគទៅកាន់សាធារណរដ្ឋប្រជាមានិតចិន............................៨៥
- សមាគមឧកញ៉ាកម្ពុជារៀបចំជំនួបផ្លូវផ្គងធុរកិច្ចនិងពិសាភោជនាហារដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសមាគមវិនិយោគិនចិនមីននៅកម្ពុជា...........................................................................................................៨៦
- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីបើកពិព័រណ៍អន្តរជាតិចិនលើកទី២៥ សម្រាប់ការវិនិយោគ និងពាណិជ្ជកម្មនៅទីក្រុងសៀមិន ខេត្តហ្វ៊ូជៀន សាធារណរដ្ឋប្រជាមានិតចិន.........................................................................៨៧
- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមសន្និសីទ Future Investment Conference 2025 Opening & Plenary Session
- និងទស្សនកិច្ចមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិក្រុងសៀមិន..........................................................៨៩
- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមវេទិកាខ្សែក្រវាត់ និងផ្លូវសម្រាប់ការផ្លាស់ប្តូរកិច្ចសហប្រតិបត្តិការវិនិយោគអន្តរជាតិ.........................................................................................................................................៩០
- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចាប់ផ្តើមបេសកកម្មនៅទីក្រុងហុងកុង តាមរយៈការចូលរួមកិច្ចប្រជុំកំពូលខ្សែក្រវាត់ និងផ្លូវលើកទី១០ (The 10th Belt and Road Summit).........................................................................................៩១
- សន្និសីទស្តីពីកិច្ចសហប្រតិបត្តិការវិនិយោគចិន-កម្ពុជារៀបចំដោយ សមាគមឧកញ៉ាកម្ពុជា និងសមាគមអ្នកវិនិយោគចិនជនជាតិមីននៅកម្ពុជាទទួលបានជោគជ័យដ៏ត្រចះត្រចង់.........................................................................៩២
- ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ដឹកនាំគណៈប្រតិភូកម្ពុជាមានសមាសភាពចូលរួមពីសមាគមឧកញ៉ាកម្ពុជា ជួបផ្លូវផ្គងធុរកិច្ចជាមួយសមាជិកសភាពាណិជ្ជកម្មចិនប្រចាំក្រុងហុងកុង.........................................................៩៤
- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងជំនួបពិភាក្សាការងារជាមួយលោកសាស្ត្រាចារ្យ Frederick Ma ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង........................................................................................................៩៥
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលពេញអង្គ លើកទី១០ អាណត្តិទី១ ត្រីមាសទី៣ ឆ្នាំ២០២៥..........................................................................................................៩៦
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីដាក់ក្រពុំបិណ្ឌផ្កាឈូកគោរពរដ្ឋធម្មនុញ្ញក្នុងឱកាសខួបលើកទី៣២ ទិវាប្រកាសរដ្ឋធម្មនុញ្ញ ...................................................................៩៩
- អ្នកឧកញ៉ា ហ៊ី បារី សមាជិកក្រុមប្រឹក្សាភិបាលដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួម «វេទិកាជំនួបរវាងក្រុមការងារជំរុញការវិនិយោគក្នុងភូមភាគឦសាន និងវិនិយោគិន»................................................................១០១

# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ាប្រធាន ដឹកនាំសមាជិកសមាគមឧកញ៉ាកម្ពុជាចំនួន ១០រូបចូលរួមសិក្ខាសាលាស្តីពី «ភាពជាដៃគូរវាងរដ្ឋ ឯកជន និងពលរដ្ឋ ដើម្បីកម្ពុជាប្រកបដោយជំនាញ»



នាថ្ងៃសុក្រ ៩កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំសមាជិកចំនួន ១០រូប ចូលរួមសិក្ខាសាលាស្តីពី "ភាពជាដៃគូរវាងរដ្ឋ ឯកជន និងពលរដ្ឋ (Public-Private-People Partnership) ដើម្បីកម្ពុជាប្រកបដោយជំនាញ" ក្រោមអធិបតីភាព ឯកឧត្តម ផាន់ ផល្លា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការចូលរួមពីតំណាងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍អន្តរជាតិ សមាគមពាណិជ្ជកម្ម ថ្នាក់ដឹកនាំរោងចក្រ-សហគ្រាស ក្រុមប្រឹក្សាជំនាញតាមវិស័យ តំបន់សេដ្ឋកិច្ចពិសេស ស្ថាប័នស្រាវជ្រាវ គ្រឹះស្ថានបណ្តុះបណ្តាល និងតំណាងយុវជនប្រមាណជាង ២០០ស្ថាប័ន។

សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងចម្បងៗរួមមាន៖ ១) ការចែករំលែកបទពិសោធល្អៗក្នុងការអភិវឌ្ឍមូលធនមនុស្សពីដៃគូយុទ្ធសាស្ត្រក្នុងតំបន់ (សិង្ហបុរី និងម៉ាឡេស៊ី), ២) ការពង្រីកការយល់ដឹងអំពីសារៈសំខាន់នៃការបង្កើនជំនាញ (Upskilling) និងផ្លាស់ប្តូរជំនាញ (Re-skilling) ដើម្បីលើកកម្ពស់សមត្ថភាព និងភាពប្រកួតប្រជែង, និង ៣) ការផ្លាស់ប្តូរកិច្ចព្រមព្រៀងជាមួយដៃគូយុទ្ធសាស្ត្រក្នុងតំបន់ និងក្នុងស្រុក។

ក្នុងសិក្ខាសាលានេះផងដែរ ក៏មានរៀបចំកិច្ចពិភាក្សាដើម្បីចែករំលែកបទពិសោធ នៃការអភិវឌ្ឍមូលធនមនុស្សជាមួយកម្មវិធីបង្កើនជំនាញ (Upskilling) និងកម្មវិធីផ្លាស់ប្តូរជំនាញ (Reskilling) របស់ប្រទេសសិង្ហបុរី និងម៉ាឡេស៊ី ក្រោមប្រធានបទ "បង្កើនជំនាញឥឡូវនេះដើម្បីប្រកួតប្រជែងថ្ងៃស្អែក! ជំនាញខ្ពស់ ចំណូលខ្ពស់!"។ ក្នុងកិច្ចពិភាក្សានេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ ក៏ត្រូវបានផ្តល់កិត្តិយសអញ្ជើញឱ្យធ្វើជាវាគ្មិនដើម្បីចែករំលែកអំពីបទពិសោធ និងបញ្ហាប្រឈមជាក់ស្តែងក្នុងការធ្វើអាជីវកម្មពាក់ព័ន្ធនឹងប្រធានបទនេះផងដែរ។ អ្នកឧកញ៉ាអគ្គលេខាធិការ បានចែករំលែកអំពីទស្សនវិស័យ បេសកកម្ម និងសកម្មភាពសំខាន់ៗរបស់សមាគមឧកញ៉ាកម្ពុជា ដែលសមាគមដើរតួនាទីយ៉ាងសកម្មក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលក្នុងការទាក់ទាញនិងជំរុញការវិនិយោគ និងលើកកម្ពស់សកម្មភាពពាណិជ្ជកម្មលើគ្រប់វិស័យ។ បន្ថែមលើនេះ អ្នកឧកញ៉ាអគ្គលេខាធិការ ក៏បានគូសរំលេចអំពីសារៈសំខាន់ និងតម្រូវការនៃកម្លាំងពលកម្មជំនាញនៅក្នុងពិភពលោកដែលកំពុងតែមានការអភិវឌ្ឍឥតឈប់ឈរ ក្នុងនោះក៏មានកម្ពុជាផងដែរដែលត្រូវការកម្លាំងពលកម្មប្រកបដោយជំនាញ និងមានវិជ្ជាជីវៈត្រឹមត្រូវទៅតាមវិស័យអាទិភាពនីមួយៗរបស់កម្ពុជាដើម្បីចូលរួមជំរុញវិស័យទាំងនោះឱ្យកាន់តែមានការអភិវឌ្ឍទៅមុខ ក៏ដូចជាទាក់ទាញវិនិយោគិនបរទេសមកដាក់ទុនវិនិយោគនៅកម្ពុជាផងដែរ។ តាមរយៈការធ្វើអាជីវកម្មអស់រយៈពេលជាច្រើនឆ្នាំកន្លងមក អ្នកឧកញ៉ាអគ្គលេខាធិការ បានចែករំលែកដល់អង្គសិក្ខាសាលាទាំងមូលអំពីបទពិសោធ និងបញ្ហាប្រឈមជាក់ស្តែងនានានៅក្នុងវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងការកែច្នៃអាហារដែលនៅខ្វះខាតកម្លាំងពលកម្មជំនាញសម្រាប់បម្រើការងារក្នុងវិស័យនេះដែលជាវិស័យអាទិភាពមួយយើងអាចកែច្នៃនិងទាញយកផលប្រយោជន៍ទ្វេដងសម្រាប់ កំណើនសេដ្ឋកិច្ចជាតិ។

អ្នកឧកញ៉ា  បានវាយតម្លៃខ្ពស់ និងជឿជាក់ថា សិក្ខាសាលានេះគឺជាការចែករំលែកបទពិសោធដ៏ល្អ និងពិតជាមានតម្លៃខ្ពស់ជួយលើកទឹកចិត្ត និងបង្កើនការចូលរួមប្រកបដោយគុណភាពរបស់វិស័យឯកជន និងពលរដ្ឋក្រោមការគាំទ្ររបស់រាជរដ្ឋាភិបាល ដើម្បីជំរុញឱ្យកម្ពុជាប្រកបដោយជំនាញនាពេលខាងមុខដ៏ខ្លី។




















# អគារសិក្សា ៥ខ្នង សរុប ៥៥បន្ទប់ ជាអំណោយរបស់សមាគមឧកញ៉ាកម្ពុជា ជូនសាលាចំនួន ៥នៅក្នុងខេត្តកំពង់ធំ ត្រូវបានប្រារព្ធពិធីបញ្ចុះបឋមសិលា បើកការដ្ឋានសាងសង់ជាផ្លូវការ



នាព្រឹកថ្ងៃសៅរ៍ ២រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៥ អ្នកឧកញ៉ា លាង ម៉េង ប្រធានក្រុមការងារសាងសង់អគារសិក្សានៅខេត្តកំពង់ធំ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយអ្នកឧកញ៉ា ឧកញ៉ា ជាអនុប្រធាន និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបទៀតបានអញ្ជើញប្រារព្ធពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារសិក្សាជាអំណោយរបស់សមាគមឧកញ៉ាកម្ពុជា ចំនួន ៥ខ្នង សរុប ៥៥បន្ទប់នៅវិទ្យាល័យទ្រៀល សាលាបឋមសិក្សាកកោះ សាលាបឋមសិក្សាជាន់លែង ភូមិថ្មី សាលាបឋមសិក្សា ហ៊ុន សែន ឈូកជីព្រះ និងសាលាបឋមសិក្សាសមាគមឧកញ៉ាម្ពុជា អូរសំបួរ ដែលនឹងប្រើប្រាស់ថវិកាប្រមាណ ១.២២២.២២២ ដុល្លារអាមេរិក។

ពិធីនេះក៏មានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម នួន ផារ័ត្ន អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ ព្រមទាំងវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំខេត្ត និងមន្ត្រីពាក់ព័ន្ធ ក៏ដូចជាលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ជាតំណាងសាលាទាំង៥ ប្រមាណជាង ៤០០នាក់ផងដែរ។

សូមបញ្ជាក់ដែរថា សមាគមឧកញ៉ាកម្ពុជា បានចាត់ទុកការចូលរួមសកម្មភាពសប្បុរិសធម៌ និងសង្គមកិច្ច គឺជាការងារអាទិភាពមួយរបស់ខ្លួនដែលបានចូលរួម និងគាំទ្រយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុត និងប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានកិត្តិយសសមាគមឧកញ៉ាកម្ពុជា។

ក្នុងឱកាសនេះដែរ សមាគមឧកញ៉ាកម្ពុជា ក៏បានឧបត្ថម្ភថវិកាលើកទឹកចិត្តជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សដែលបានចូលរួមក្នុងកម្មវិធីនេះផងដែរដោយចំពោះគ្រូបង្រៀនចំនួន ២០នាក់ម្នាក់ៗទទួលបានថវិកា ១០ម៉ឺនរៀល ចំណែកឯសិស្សានុសិស្សចំនួន ២០០នាក់ក្នុងម្នាក់ទទួលបានថវិកា ៤ម៉ឺនរៀល បន្ថែមពីលើនេះ អ្នកឧកញ៉ា លាង ម៉េង ក៏បានចូលរួមឧបត្ថម្ភទឹកពិសាបរិសុទ្ធកម្ពុជាសរុបចំនួន ៣០០កេស ដើម្បីប្រើប្រាស់ក្នុងកម្មវិធីទាំងមូលក៏ដូចជាចែកជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សម្នាក់ ១កេសផងដែរ។

គួររំលឹកដែរថា សម្រាប់សកម្មភាពសប្បុរិសធម៌ ឆ្នាំ២០២៥ ក្រោមប្រធានបទ «ទាំងអស់គ្នាដើម្បីការអប់រំ» នៅលើទឹកដីខេត្តកំពង់ធំនេះដែរ សមាគមឧកញ៉ាកម្ពុជា បានកៀរគរនូវធនធានជាថវិកា និងសម្ភារៈប្រមាណជិត ២លានដុល្លារអាមេរិកដែលជាការបរិច្ចាគរបស់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាសមាជិករបស់សមាគមដើម្បីជួយកសាងអគារសិក្សាក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធផ្សេងៗព្រមទាំងឧបត្ថម្ភជាសម្ភារៈសិក្សា សម្លៀកបំពាក់ មធ្យោបាយធ្វើដំណើរ ដល់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សនៃសាលាទាំង១០ ដោយក្នុងនោះមានសាលាចំនួន ៥ដែល

ទទួលបានអគារសិក្សាដើម្បីបំពេញតម្រូវការស្របទៅតាមភាពកង្វះខាត និងការលំបាកក្នុងការផ្តល់ថ្នាក់រៀនដល់សិស្សានុសិស្សដែលតែងតែមានកំណើនជារៀងរាល់ឆ្នាំដោយវិទ្យាល័យទ្រៀលទទួលបានអគា១ខ្នង កម្ពស់៣ជាន់ មាន ៣០បន្ទប់, សាលាបឋមសិក្សាកកោះ ទទួលបានអគារ១ខ្នង កម្ពស់ ២ជាន់ មាន ១០បន្ទប់ ចំណែកសាលាបឋមសិក្សាជាន់លែង ភូមិថ្មី សាលាបឋមសិក្សា ហ៊ុន សែន ឈូកជីព្រះ និងសាលាបឋមសិក្សាសមាគមឧកញ៉ាម្ពុជា អូរសំបួរ ទទួលបានអគារ ១ខ្នង កម្ពស់ ១ជាន់មាន ៥បន្ទប់ដូចៗគ្នា៕




























# អ្នកឧកញ៉ា គួន ធីតា ដឹកនាំសមាជិក នៃសមាគមឧកញ៉ាកម្ពុជាចូលរួម ពិធីផ្សព្វផ្សាយ «របាយការណ៍វឌ្ឍនភាព នៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ ប្រចាំឆមាសទី២ ឆ្នាំ២០២៤ និងពិធីអបអរសាទរខួបគម្រប់ ២៥ឆ្នាំ នៃកិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងផ្នែកឯកជន»



នារសៀលថ្ងៃព្រហស្បតិ៍ ទី១៧ ខែកក្កដា ឆ្នាំ២០២៥ អ្នកឧកញ៉ា គួន ធីតា សមាជិកក្រុមប្រឹក្សាភិបាល និងជាប្រធានអនុគណៈកម្មការទំនាក់ទំនង និងធុរកិច្ច ព្រមទាំងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយអ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជាជាច្រើនរូប បានចូលរួមក្នុងពិធីផ្សព្វផ្សាយ «របាយការណ៍វឌ្ឍនភាព នៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ ប្រចាំឆមាសទី២ ឆ្នាំ២០២៤» និងពិធីអបអរសាទរខួបគម្រប់២៥ឆ្នាំ នៃកិច្ចសន្ទនារវាងរាជរដ្ឋាភិបាល និងផ្នែកឯកជន ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល និងជាប្រធានគណៈកម្មាធិការសម្របសម្រួលការងារសម្រាប់យន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (គ.ស.រ.ជ.)។

សូមបញ្ជាក់ថា «របាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ ប្រចាំឆមាសទី២ ឆ្នាំ២០២៤» ដែលប្រារព្ធពិធីផ្សព្វផ្សាយនាឱកាសនេះ ត្រូវបានអនុម័តជាផ្លូវការដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៥ កន្លងទៅ។ របាយការណ៍បានលម្អិតពីវឌ្ឍនភាពលើកំណែទម្រង់វិស័យជាអាទិភាពរួមមានការសម្រួលពាណិជ្ជកម្ម ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម និងការកែលម្អបទប្បញ្ញត្តិពាក់ពន្ធនឹងវិស័យគយ និងរដ្ឋាករ។

ជាលទ្ធផល មានបញ្ហាសរុបចំនួន១១៥ ត្រូវបានលើកឡើង ក្នុងនោះបញ្ហាចំនួន៧៩ ស្មើនឹងប្រមាណ៦៩% ត្រូវបានដោះស្រាយ រីឯបញ្ហាចំនួន៣៦ ស្មើនឹងប្រមាណ៣១% កំពុងត្រូវបានបន្តដោះស្រាយ។ នៅក្នុងរបាយការណ៍ ក៏បានផ្តល់នូវទិដ្ឋភាពទូទៅនៃសកម្មភាពនានារបស់ ក្រសួង ស្ថាប័ន និងក្រុមការងារវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ហើយបានគូសបញ្ជាក់ពីជំហានឆ្ពោះទៅកាន់កិច្ចប្រជុំពេញអង្គវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី២០ ដែលគ្រោងនឹងប្រព្រឹត្តទៅនៅឆ្នាំ២០២៦ ខាងមុខ។




ថ្លែងទៅកាន់អង្គពិធី ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានលើកឡើងអំពីចំនួនគម្រោងវិនិយោគដែល ក.អ.ក. បានអនុម័តនៅក្នុងឆមាសទី១ ឆ្នាំ២០២៥ ដែលបង្ហាញពីសញ្ញាណវិជ្ជមានឈានទៅបំបែកកំណត់ត្រាសារជាថ្មីម្តងទៀតក្នុងបំណាច់ឆ្នាំ២០២៥ខាងមុខ។ ឯកឧត្តមបានបន្ថែមថា កំណើនចំនួនគម្រោងវិនិយោគបានស្តែងឱ្យឃើញពីគុណសម្បត្តិនៃបរិយាកាសវិនិយោគនៅកម្ពុជា ក្រោមការយកចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាល និងការអនុវត្តឌីជីថលូបនីយកម្មក្នុងដំណើរការត្រួតពិនិត្យនិងអនុម័តគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមរយៈប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា cdcIPM ដែលជួយកាត់បន្ថយការចំណាយ ពេលវេលា និងបង្កើនភាពច្បាស់លាស់ក្នុងជំហាននីមួយៗ។

ជាមួយគ្នានេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានរំលេចជាពិសេសអំពីមុខងារថ្មីនៅក្នុងប្រព័ន្ធនោះគឺការប្រថាប់ត្រាអេឡិចត្រូនិក (e-Stamp) និងការចុះ ហត្ថលេខាអេឡិចត្រូនិក (e-Signature) ដែលអនុញ្ញាតឱ្យថ្នាក់ដឹកនាំអាចធ្វើការចុះហត្ថលេខាអនុម័ត និងប្រថាប់ត្រាបានពីគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាម រយៈមុខងារថ្មីទាំងនេះ។

គួររំលឹកដែរថា វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន គឺជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបើកទូលាយដែលត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ១៩៩៩ ក្រោមគំនិតផ្តួចផ្តើមប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាតេជោ ហ៊ុន សែន** ដោយយន្តការនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុញ្ញាតឱ្យផ្នែកឯកជនបានលើកឡើងនូវសំណូមពរ និងបញ្ហាប្រឈមដើម្បីស្នើសុំដំណោះស្រាយ និងអន្តរាគមន៍ពីផ្នែករាជរដ្ឋាភិបាលសំដៅចូលរួមលើកកម្ពស់បរិយាកាសធុរកិច្ចនៅកម្ពុជា តាមរយៈកិច្ចសន្ទនាដែលមានរចនាសម្ព័ន្ធច្បាស់លាស់ប្រកបដោយតម្លាភាពរវាងរាជរដ្ឋា ភិបាល និងផ្នែកឯកជន។









# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំសមាជិកសមាគមឧកញ៉ាកម្ពុជា ចូលរួម «ពិព័រណ៍អាពាហ៍ពិពាហ៍លើកទី២ ប្រចាំឆ្នាំ២០២៥» ក្រោមអធិបតីភាព លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត












នាព្រឹកថ្ងៃសុក្រ ទី១៨ ខែកក្កដា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវបានដឹកនាំលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាថ្នាក់ដឹកនាំ ក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូប ចូលរួមក្នុងព្រឹត្តិការណ៍ពិព័រណ៍អាពាហ៍ពិពាហ៍ដ៏លើកទី ២ ប្រចាំឆ្នាំ២០២៥ នៅមជ្ឈមណ្ឌល ដឹ ព្រេមៀ សែនធ៌រ សែនសុខ ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត។**

មហាព្រឹត្តិការណ៍ដ៏ធំនេះមានបណ្តុំទៅដោយក្រុមហ៊ុនផ្តល់សេវាកម្មរៀបចំពិធីមង្គលការដ៏សម្បូរបែបរួមមានទាំងសម្អាងការ ចុងភៅ ពិធីការ ការតុបតែង ថតរូប ភេសជ្ជៈ គ្រឿងអលង្ការ ពោលគឺប្រមូលផ្តុំគ្រប់សេវាកម្មអាពាហ៍ពិពាហ៍ទាំងអស់មកដាក់តាំងបង្ហាញពីផលិតផល និងសេវាកម្មនីមួយៗរយៈពេលបីថ្ងៃនៅមជ្ឈមណ្ឌល ដឹ ព្រេមៀ សែនធ៌រ សែនសុខ រាជធានីភ្នំពេញចាប់ពីថ្ងៃទី១៨-២០ ខែកក្កដានេះ។

ជាការកត់សម្គាល់ មហាព្រឹត្តិការណ៍នេះក៏ជាផ្នែកមួយក្នុងការផ្សព្វផ្សាយ វប្បធម៌ និងប្រពៃណីអាពាហ៍ពិពាហ៍ខ្មែរដែលជាអត្តសញ្ញាណជាតិដែលមិនអាចខ្វះបាន ជាពិសេស ការបង្ហាញទម្រង់សម្លៀកបំពាក់ប្រពៃណីស្របតាមពេលវេលា និងសម័យកាលប្រកបដោយក្រឹតក្រមបានត្រឹមត្រូវបំផុត ព្រមទាំងការរៀបចំនូវវេទិកាតុពិភាក្សាទាក់ទងនឹងចំណេះដឹងជាច្រើនទៀតដូចជា ការយល់ដឹងពីប្រវត្តិភ្លេងការ ទំនៀមទម្លាប់ដេញពេលវេលាថ្ងៃរៀបមង្គលការ និងសេដ្ឋកិច្ចប្រចាំថ្ងៃទាក់ទងនឹងសេវាកម្មផ្គត់ផ្គង់អាពាហ៍ពិពាហ៍ផងដែរ។

# សមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួម «សន្និសីទស្តីពីការបង្កើតកិច្ចសហការរួមគ្នាកម្ពុជា-ជប៉ុន លើកទី៣ ឆ្ពោះទៅកាន់ការបង្កើតប្រព័ន្ធអេកូឡូស៊ីនិងនវានុវត្តន៍ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថលបៃតង និងលំហអាកាសមកពីប្រទេសជប៉ុន»

នាថ្ងៃព្រហស្បតិ៍ ១៤រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ សមាជិកសមាគមឧកញ៉ាកម្ពុជា បានចូលរួម "សន្និសីទស្តីពីការបង្កើតកិច្ចសហការរួមគ្នាកម្ពុជា-ជប៉ុន លើកទី៣ ឆ្ពោះទៅកាន់ការបង្កើតប្រព័ន្ធអេកូឡូស៊ី និងនវានុវត្តន៍ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល បៃតង និងលំហអាកាសមកពីប្រទេសជប៉ុន" ដែលប្រារព្ធធ្វើឡើងនៅសណ្ឋាគារ Hyatt Regency ភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជាដោយមានការចូលរួមពីតំណាងក្រសួង-ស្ថាប័នរដ្ឋាភិបាល សភាពាណិជ្ជកម្ម សមាគម និងវិស័យឯកជនកម្ពុជា-ជប៉ុនជាច្រើនរូប។

សន្និសីទនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីការបង្កើតប្រព័ន្ធអេកូឡូស៊ី និងនវានុវត្តន៍ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល បៃតង និងលំហអាកាសមកពីប្រទេសជប៉ុន ព្រមទាំងពង្រឹងនិងពង្រីកទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា និងជប៉ុន តាមរយៈការផ្គូផ្គងធុរកិច្ចពាក់ព័ន្ធឥណទានកាបូនក្នុងវិស័យអាទិភាព ដូចជា កសិកម្ម កសិ-ឧស្សាហកម្ម និងបច្ចេកវិទ្យាជាដើម។ នេះជាសន្និសីទលើកទី៣ហើយដែលត្រូវបានរៀបចំឡើងក្រោមកិច្ចសហការរវាងអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន ( JETRO ) និង ទីភ្នាក់ងាររុករកលំហអាកាសជប៉ុន ( JAXA ) ដោយមានការគាំទ្រពីភាគីកម្ពុជា ហើយក៏មានរៀបចំការផ្គូផ្គងធុរកិច្ចជាមួយក្រុមហ៊ុនជប៉ុនចំនួន៧ ដែលសុទ្ធសឹងជាក្រុមហ៊ុនមានបទពិសោធ និងជំនាញផ្នែកបច្ចេកវិទ្យាកសិកម្មផងដែរ។















ថ្លែងក្នុងសន្និសីទនេះ ឯកឧត្តមរដ្ឋមន្ត្រី បានគូសបញ្ជាក់លើយន្តការសំខាន់ៗរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុដែលរួមមានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ពីវិស័យសំខាន់ៗរួមមានថាមពល ផលិតកម្មឧស្សាហកម្ម កសិកម្ម ព្រៃឈើ និងសំណល់។ ឥណ ទានទាំងនេះអាចធ្វើពាណិជ្ជកម្មសម្រាប់ប្រទេសមួយចំនួនដែលត្រូវការសម្រាប់ប្រើប្រាស់ដើម្បីសម្រេចគោលដៅផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (NDC) ដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ ជាមួយគ្នានេះ កម្ពុជាក៏មានគោលដៅប្រែក្លាយជាប្រទេសអព្យាក្រឹតភាពកាបូននៅឆ្នាំ២០៥០ ផងដែរ។

សូមជម្រាបជូនដែរថា កម្ពុជាបានដាក់ចេញនូវផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាដំណាក់កាលដោយក្នុងនោះមានផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាដំណាក់កាលទី១ (iNDC) កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រមាណ ២៧%។ បច្ចុប្បន្នភាពផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាដំណាក់កាលទី២ (NDC 2.0) កំណត់គោលដៅកាត់បន្ថយ ៤២.៧% ពីវិស័យចំនួន ៥ ដោយមិនទាន់បានដាក់បញ្ចូលវិស័យគីមី/សារធាតុរំលាយ និងផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាដំណាក់កាលទី៣ (NDC 3.0) ដែលកំពុងរៀបចំដាក់ជូនលេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ដោយកំណត់គោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រមាណ ៥៧% ហើយដើម្បីសម្រេចគោលដៅទាំងនេះ កម្ពុជាត្រូវការថវិកាពីដៃគូ និងសហគមន៍អន្តរជាតិ។ បច្ចុប្បន្ននេះក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) កំពុងខិតខំរៀបចំខ្លួនឱ្យក្លាយជាអង្គភាពមានសម្បទា (Accredited Entity) សម្រាប់មូលនិធិអាកាសធាតុបៃតង (Green Climate Fund) ដែលនឹងទទួលហិរញ្ញប្បទានដោយផ្ទាល់ដើម្បីឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុសកល។












# សមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួម «វេទិកាជំរុញផ្សព្វផ្សាយស្ទួនឧស្សាហកម្មកម្ពុជា-ចិន» ក្រោមអធិបតីភាព លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម



នារសៀលថ្ងៃចន្ទ ៣កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ សមាជិកសមាគមឧកញ៉ាកម្ពុជា បានចូលរួម "វេទិកាជំរុញផ្សព្វផ្សាយស្ទួនឧស្សាហកម្មកម្ពុជា-ចិន" ដោយប្រារព្ធធ្វើឡើងនៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាព លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលមានវត្តមានអញ្ជើញចូលរួមដោយ ឯកឧត្តម ចឹង យ័នតុង (Zheng Yuandong) អគ្គលេខាធិការរង នៃរដ្ឋាភិបាលប្រជាជន នៃតំបន់ស្វយ័តជនជាតិជាំងក្វាងស៊ី លោកស្រី ចឹង លីង (Zheng Ling) អភិបាលរងទីក្រុងប៉ីហាយ នៃតំបន់ស្វយ័តជនជាតិជាំងក្វាងស៊ី ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈប្រតិភូរដ្ឋាភិបាលតំបន់ស្វយ័តជនជាតិជាំងក្វាងស៊ី និងវិនិយោគិន-ធុរជនកម្ពុជានិងចិនជាច្រើនរូប។












វេទិកានេះត្រូវបានសហការរៀបចំឡើងដោយក្រសួងពាណិជ្ជកម្ម និងក្រុមការងាររបស់តំបន់ស្វយ័តជនជាតិជាំងក្វាងស៊ីនៃសាធារណរដ្ឋប្រជាមានិតចិនក្នុងគោលបំណងផ្សព្វផ្សាយ និងផ្សារភ្ជាប់ទំនាក់ទំនងរវាងវិស័យឯកជនកម្ពុជា-ចិន ដើម្បីជំរុញពន្លឿនការសាងសង់សួនឧស្សាហកម្ម កម្ពុជា-ចិន ទាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅក្នុងសាធារណរដ្ឋប្រជាមានិតចិនស្របតាមស្មារតីនៃអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការកសាងសួនឧស្សាហកម្មកម្ពុជា-ចិន ដែលត្រូវបានចុះហត្ថលេខាដោយក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងតំបន់ស្វយ័តជនជាតិជាំងក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន កាលពីខែតុលា ឆ្នាំ២០២៣ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន ក្រោមសក្ខីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម ស៊ី ជីនពីង ប្រធានា ធិបតី នៃសាធារណរដ្ឋប្រជាមានិតចិន។

ថ្លែងក្នុងវេទិកាដ៏មានសារៈសំខាន់នេះ លោកជំទាវរដ្ឋមន្ត្រី ក៏បានលើកទឹកចិត្តឱ្យក្រុមការងារចម្រុះសាងសង់សួនឧស្សាហកម្មកម្ពុជា-ចិន ជួបប្រជុំពិភាក្សាឱ្យបានទៀងទាត់ និងញឹកញាប់ដោយកំណត់ផែនការសកម្មភាពឱ្យបានជាក់លាក់ ដើម្បីអាចសម្រេចបានតាមផែនការដែលបានគ្រោងទុក និងរៀបចំព្រឹត្តិការណ៍ពាណិជ្ជកម្មនានាឱ្យបានជាប្រចាំនិងញឹកញាប់ទាំងនៅកម្ពុជានិងនៅចិនដើម្បីបង្កើនឱកាសក្នុងការចាប់ដៃគូធុរកិច្ច និងវិនិយោគ ព្រមទាំងជំរុញនិងលើកទឹកចិត្តឱ្យវិនិយោគិនចិនមកបណ្ដាក់ទុនធ្វើប្រតិបត្តិការអាជីវកម្មឱ្យកាន់តែច្រើនឡើងបន្ថែមទៀតនៅកម្ពុជា ជាពិសេសក្នុងវិស័យមានសក្ដានុពលខ្ពស់ ដែលអាចថ្លក់ទៅនឹងខ្សែច្រវាក់ផលិតកម្មនៅប្រទេសចិន ដូចជាកសិកម្មទំនើប ឧស្សាហកម្មកែច្នៃចំណីអាហារវិស័យយានយន្ត អេឡិចត្រូនិក និងបច្ចេកវិទ្យាឌីជីថល ជាដើមសំដៅលើការបង្កើនទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។

ជាមួយគ្នានេះ លោកជំទាវរដ្ឋមន្ត្រី បានលើកទឹកចិត្តឱ្យវិស័យឯកជននៃប្រទេសទាំងពីរទាញយកប្រយោជន៍ឱ្យបានជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលប្រទេសទាំងពីរជាសមាជិកជាពិសេសកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ដែលទើបបញ្ចប់ការចរចាដំឡើងកម្រិត និងគ្រោងចុះហត្ថលេខាក្នុងពេលឆាប់ៗខាងមុខនេះ និងជាពិសេសកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិនដែលគណៈកម្មការចម្រុះនៃប្រទេសទាំងពីរគ្រោងនឹងជួបប្រជុំលើកទី២នៅដើមខែកញ្ញា ឆ្នាំ២០២៥នេះ។ ឆ្លៀតក្នុងឱកាសនេះដែរ លោកជំទាវរដ្ឋមន្ត្រី ក៏បានអញ្ជើញផ្ដល់កិត្តិយសចូលរួមធ្វើជាសក្ខីភាពក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអាជីវកម្ម ចំនួន៩ រវាងក្រុមហ៊ុនកម្ពុជា និងចិន ក្នុងគោលបំណងជំរុញការវិនិយោគបន្ថែមលើវិស័យសំខាន់ៗ ដូចជា ថាមពលថ្មីវិស័យកាត់ដេរ ការកែច្នៃ និងជំរុញការនាំចេញផលិតផលសក្ដានុពលកម្ពុជាទៅកាន់ទីផ្សារប្រទេសចិន ក៏ដូចជាផ្សព្វផ្សាយនិងលើកកម្ពស់វិស័យទេសចរណ៍ និងវប្បធម៌រវាងប្រទេសទាំងពីរផងដែរ។







# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តមឧត្តមសេនីយ៍ឯក ដួង សំនៀង ដែលបានពលីក្នុងសមរភូមិនាខេត្តព្រះវិហារ

នាថ្ងៃព្រហស្បតិ៍ ទី៣១ ខែកក្កដា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តមឧត្តមសេនីយ៍ឯក ដួង សំនៀង មេបញ្ជាការកងពល តូចអន្តរាគមន៍លេខ៧ដែលបានពលីជីវិតក្នុងបុព្វហេតុជាតិមាតុភូមិនៅសមរភូមិប្រយុទ្ធខេត្តព្រះវិហារប្រឆាំងនឹងកងទ័ពឈ្លានពានថៃកាលពីរសៀលថ្ងៃសៅរ៍ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥ ក្នុងជន្មាយុ ៦៧ឆ្នាំ។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានពាំនាំនូវការចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធានក៏ដូចជាលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជាជូនចំពោះលោកជំទាវ អ៊ុក ស៊ុនរ៉ានី ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ឯកឧត្តមឧត្តមសេនីយ៍ឯក ដួង សំនៀង ដែលជាស្វាមី ជាឪពុកបង្កើត ឪពុកក្មេក និងជីតា ប្រកបដោយព្រហ្មវិហារធម៌មួយរូប ព្រមទាំងជាវីរជនដ៏អង់អាចក្លាហានពោរពេញដោយស្មារតីស្នេហាជាតិមាតុភូមិ។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ ឯកឧត្តមឧត្តមសេនីយ៍ឯក ដួង សំនៀង សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។ វីរភាពដ៏អង់អាចរបស់ឯកឧត្តមនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបាន។













# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរព វិញ្ញាណក្ខន្ធ លោកអនុសេនីយ៍ឯក ពោ វៃ ដែលបានពលីក្នុងសមរភូមិ

នាថ្ងៃព្រហស្បតិ៍ ទី៣១ ខែកក្កដា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធាន ប្រធានសមាគមឧកញ៉ាកម្ពុជា បានបន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលរួមមានសមាសភាព អ្នកឧកញ៉ា និងឧកញ៉ា ជាច្រើនរូប ចូលរួមគោរពវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ឯក ពោ វៃ យោធិននៃកងពលតូចអន្តរាគមន៍លេខ៨ ចំណុះកងពលធំអន្តរាគមន៍លេខ៣ កងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទដែលបានពលីជីវិតក្នុងបុព្វហេតុជាតិមាតុភូមិនៅសមរភូមិប្រយុទ្ធប្រឆាំងនឹងកងទ័ពឈ្លានពានថៃ ចំណែកឯពិធីបុណ្យសពកំពុងប្រារព្ធធ្វើនៅវត្តវាលស្បូវ។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានពាំនាំនូវការចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ជូនក្រុមគ្រួសារ នៃសពចំពោះមរណភាពរបស់លោកអនុសេនីយ៍ឯក ពោ វៃ ដែលជាស្វាមី និងជាឪពុកមួយរូបដែលប្រកបដោយព្រហ្មវិហារធម៌ព្រមទាំងជាវីរជនដ៏អង់អាចក្លាហានពោរពេញដោយស្មារតីស្នេហាជាតិមាតុភូមិ។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ លោកអនុសេនីយ៍ឯក ពោ វៃ សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។ វីរភាពដ៏អង់អាចរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបាន។








# អ្នកឧកញ៉ា អ៊ាន អេឡែន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ បន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ លោកអនុសេនីយ៍ត្រី ច័ន្ទ តារា ដែលបានពលីក្នុងសមរភូមិភ្នំទ្រព្យ

នាព្រឹកថ្ងៃសៅរ៍ ទី២ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា អ៊ាន អេឡែន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ អនុសេនីយ៍ត្រី ច័ន្ទ តារា ដែលបានពលីជីវិតក្នុងសមរភូមិនៅភ្នំទ្រព្យក្នុងបុព្វហេតុការពារបូរណភាពទឹកដីតទល់នឹងកងទ័ពឈ្លានពានសៀម។

ក្នុងវេលាដ៏ក្រៀមក្រំនេះ អ្នកឧកញ៉ា អ៊ាន អេឡែន បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ជូនក្រុមគ្រួសារ នៃសពនៅឯស្រុកកំណើតដែលស្ថិតនៅស្រុកសូទ្រនិគម ខេត្តសៀមរាប។

មរណភាពរបស់អនុសេនីយ៍ត្រី ច័ន្ទ តារា គឺជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យនិងបូរណភាពទឹកដី។ វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ អនុសេនីយ៍ត្រី ច័ន្ទ តារា សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។













# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ លោកព្រឹទ្ធបាលឯកឌី សេង នៅស្រុកបារាយណ៍ ខេត្តកំពង់ធំ

នាព្រឹកថ្ងៃសៅរ៍ ទី២ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ លោកព្រឹទ្ធបាលឯក ឌី សេង ដែលបានពលីជីវិតក្នុងសមរភូមិភ្នំទ្រព្យក្នុងបុព្វហេតុការពារបូរណភាពទឹកដីតទល់នឹងកងទ័ពឈ្លានពានសៀម។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ជូនក្រុមគ្រួសារ នៃសពនៅឯគេហដ្ឋានផ្ទាល់ដែលស្ថិតនៅភូមិកំពង់ពោធិ៍ ឃុំបាក់ស្នា ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

មរណភាពរបស់ លោកព្រឹទ្ធបាលឯក ឌី សេង គឺជាការបាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យនិងបូរណភាពទឹកដី។ វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ លោកព្រឹទ្ធបាលឯក ឌី សេង សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។








# អ្នកឧកញ៉ា អ៊ាន អៃឡេន ជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធវីរកងទ័ពពលីចំនួន ៤រូបនៅវត្តប្រាសាទរាជាសំរោង ខេត្តឧត្តរមានជ័យ

នារសៀលថ្ងៃសៅរ៍ ទី២ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា អ៊ាន អៃឡេន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធសពវីរកងទ័ពកម្ពុជាដែលបានពលីជីវិតដើម្បី ជាតិមាតុភូមិក្នុងការវាយបកប្រឆាំងទាហានសៀមឈ្លានពានចំនួន ៤រូបគឺ៖

១. លោកព្រឹន្ទបាលឯក សយ ប្រុស

២. ពលទោ សំសុគង់ ឆាត

៣. ពលទោឯក វិន សុខា៉

៤. លោកព្រឹន្ទបាលឯក គុត ប៊ុនយឿន

ដោយពិធីបុណ្យបានប្រារព្ធធ្វើនៅវត្តប្រាសាទរាជាសំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

មរណភាពរបស់វីរជនទាំង ៤រូបគឺជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពរបស់លោកទាំងអស់គ្នានឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

សូមឧទ្ទិសបបួងសួងដល់ដួងវិញ្ញាណក្ខន្ធយោធិនពលីទាំង ៤រូបសូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។










# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ លោកអនុសេនីយ៍ត្រី ញាត ឈីន នៅស្រុកសណ្ដាន់ ខេត្តកំពង់ធំ

នាថ្ងៃសៅរ៍ ទី២ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានបន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ត្រី ញាត ឈីន ដែលបានពលីជីវិតក្នុងសមរភូមិភ្នំទ្រព្យក្នុងបុព្វហេតុការពារបូរណភាពទឹកដីតទល់នឹងកងទ័ពឈ្លានពានសៀម។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ បាននាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ជូនក្រុមគ្រួសារ នៃសពនៅឯគេហដ្ឋានផ្ទាល់ដែលស្ថិតនៅភូមិបឹង ឃុំមានរិទ្ធ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។

មរណភាពរបស់ លោកអនុសេនីយ៍ត្រី ញាត ឈីន គឺជាការបាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយាជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនទាំង ៥នាក់ហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ លោកអនុសេនីយ៍ត្រី ញាត ឈីន សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។









# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរព វិញ្ញាណក្ខន្ធលោកព្រឹន្ទបាលឯក ពេជ្រ ង៉ោល នៅស្រុកសណ្ដាន់ ខេត្តកំពង់ធំ

កាលពីថ្ងៃសៅរ៍ ទី២ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានបន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ លោកព្រឹន្ទបាលឯក ពេជ្រ ង៉ោល យោធិន នៅអង្គភាពវរសេនាតូចលេខ៣៨២ កងពលលេខ៨ ចំណុះកងពលធំលេខ ៣ ដែលបានពលីជីវិតកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥ ក្នុងសមរភូមិតទល់នឹងកងទ័ពឈ្លានពានសៀម។

ក្នុងវេលាដ៏ក្រៀមក្រំនេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ក៏ដូចជាគ្រឿងឧបភោគបរិភោគមួយចំនួនទៀតជូនក្រុមគ្រួសារ នៃសពនៅឯគេហដ្ឋានផ្ទាល់ដែលស្ថិតនៅភូមិរំពុះ ឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។ មរណភាពរបស់ លោកព្រឹន្ទបាលឯក ពេជ្រ ង៉ោល គឺជាការបាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។








# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ លោកវរសេនីយ៍ត្រី ជួង លៀប ដែលបានពលីនៅសមរភូមិប្រាសាទតាមាន់ធំ

កាលពីថ្ងៃសៅរ៍ ទី២ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានបន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ លោកវរសេនីយ៍ត្រី ជួង លៀប ដែលបានពលីជីវិតជូនជាតិមាតុភូមិក្នុងសមរភូមិនៅព្រំដែនតំបន់ប្រាសាទតាមាន់ធំ ខេត្តឧត្តរមានជ័យ កាលពីថ្ងៃព្រហស្បតិ៍ ទី២៤ ខែកក្កដា ឆ្នាំ២០២៥ ក្នុងជន្មាយុ ៥១ឆ្នាំ។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ក៏ដូចជាគ្រឿងឧបភោគបរិភោគមួយចំនួនទៀតជូនក្រុមគ្រួសារ នៃសពនៅឯភូមិព្រំស្រី ឃុំរុងរឿង ស្រុកស្ទោង ខេត្តកំពង់ធំ។ បន្ថែមពីលើនេះ សមាគមឧកញ៉ាកម្ពុជា នឹងធ្វើការផ្តល់ជូននូវអំណោយផ្ទះ ១ខ្នងជូនដល់ភរិយា និងកូនៗរបស់លោកវរសេនីយ៍ត្រី ជួង លៀប ផងដែរដោយតែគ្រួសារនេះមិនទាន់មានផ្ទះផ្ទាល់ខ្លួនសម្រាប់រស់នៅប្រចាំថ្ងៃនៅឡើយទេ។

មរណភាពរបស់ លោកវរសេនីយ៍ត្រី ជួង លៀប គឺជាការបាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ លោកវរសេនីយ៍ត្រី ជួង លៀប សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។















# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរព វិញ្ញាណក្ខន្ធលោកព្រឹន្ទបាលឯក ថា សុភា នៅស្រុកសូទ្រនិគម ខេត្តសៀមរាប

កាលពីថ្ងៃសៅរ៍ ទី២ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានបន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ លោកព្រឹន្ទបាលឯក ថា សុភា ដែលបានពលីជីវិតជូនជាតិមាតុភូមិក្នុងសមរភូមិតទល់នឹងកងទ័ពឈ្លានពានសៀម។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ព្រមទាំងគ្រឿងឧបភោគបរិភោគមួយចំនួនទៀតជូនក្រុមគ្រួសារ នៃសពនៅឯពិធីបុណ្យដែលកំពុងប្រារព្ធធ្វើឡើងនៅវត្តស្វាយលើ ក្នុងស្រុកសូទ្រនិគម ខេត្តសៀមរាប ខណៈដែលសពបានធ្លាក់ជ្រោះនិងមិនទាន់បានរកឃើញនៅឡើយ។

មរណភាពរបស់ លោកព្រឹន្ទបាលឯក ថា សុភា គឺជាការបាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ លោកព្រឹន្ទបាលឯក ថា សុភា សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។















# ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណារ័ត្ន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ លោកពលបាលឯកឈូក វ៉ាន់ត្រួយ នៅស្រុកអង្គរជ័យ ខេត្តកំពត

នាព្រឹកថ្ងៃអាទិត្យ ទី៣ ខែសីហា ឆ្នាំ២០២៥ ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណារ័ត្ន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ លោកពលបាលឯក ឈូក វ៉ាន់ត្រួយ ដែល បានពលីជីវិតជូនជាតិមាតុភូមិក្នុងសមរភូមិភ្នំទ្រព្យខេត្តព្រះវិហារតទល់នឹងកងទ័ពឈ្លានពានសៀមកាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ ក្នុងជន្មាយុ ៤៤ឆ្នាំ។

ក្នុងវេលាដ៏ក្រៀមក្រំនេះ ឧកញ៉ាវេជ្ជបណ្ឌិត បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ជូនក្រុមគ្រួសារនៃសពនៅឯពិធីបុណ្យដែលកំពុងប្រារព្ធធ្វើឡើងនៅគេហដ្ឋានផ្ទាល់ដែលស្ថិតនៅភូមិសាតំបង ឃុំដើមដូង ស្រុកអង្គជ័យ ខេត្តកំពត។

មរណភាពរបស់លោកពលបាលឯក ឈូក វ៉ាន់ត្រួយ គឺជាការបាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ លោកពលបាលឯក ឈូក វ៉ាន់ត្រួយ បានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។










# ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណារ័ត្ន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ បន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរព វិញ្ញាណក្ខន្ធលោកអនុសេនីយ៍ត្រី ចាន់ រដ្ឋធា នៅស្រុកដំណាក់ចង្អើរ ខេត្តកែប

នាព្រឹក ថ្ងៃអាទិត្យ ទី៣ ខែសីហា ឆ្នាំ២០២៥ ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណារ័ត្ន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ត្រី ចាន់ រដ្ឋធា ពលទាហាននៃបញ្ជាការដ្ឋានទ័ពពិសេសឆ័ត្រយោង ៩១១ កងទ័ពជើងគោក ដែលបានពលីកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។

ក្នុងវេលាដ៏ក្រៀមក្រំនេះ ឧកញ៉ាវេជ្ជបណ្ឌិត បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ជូនក្រុមគ្រួសារនៃសពនៅឯពិធីបុណ្យដែលកំពុងប្រារព្ធធ្វើឡើងនៅគេហដ្ឋានផ្ទាល់ដែលស្ថិតនៅឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។

មរណភាពរបស់លោកអនុសេនីយ៍ត្រី ចាន់ រដ្ឋធា គឺជាការបាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុក ប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យនិងបូរណភាពទឹកដី។ វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជា ជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

សូមឧទ្ទិសបបួងសួងដល់ដួងវិញ្ញាណក្ខន្ធ លោកអនុសេនីយ៍ត្រី ចាន់ រដ្ឋធា បានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។
















# អ្នកឧកញ៉ា គួន ធីតា សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរព វិញ្ញាណក្ខន្ធលោកវរសេនីយ៍ត្រី អ៊ួន ហាច នៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

នាថ្ងៃអាទិត្យ ទី៣ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា គួន ធីតា សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ លោកវរសេនីយ៍ត្រី អ៊ួន ហាច មេបញ្ជាការរងគ៣ វរសេនាតូចលេខ២ កងពលតូចអន្តរាគមន៍លេខ១ដែលបានពលីជីវិតនៅលើសមរភូមិប្រយុទ្ធដើម្បីការពារបូរណភាពទឹកដីកម្ពុជាពីទ័ពឈ្លានពានសៀម។

ក្នុងវេលាដ៏ក្រៀមក្រំនេះ  អ្នកឧកញ៉ា បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខ និងថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជា ព្រមទាំងគ្រឿងឧបភោគបរិភោគមួយចំនួនទៀតជូនក្រុមគ្រួសារ ជូនក្រុមគ្រួសារ នៃសពនៅគេហដ្ឋានផ្ទាល់ដែលស្ថិតនៅក្នុងភូមិស្វាយដូនកែវ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។

មរណភាពរបស់ លោកវរសេនីយ៍ត្រី អ៊ួន ហាច គឺជាការបាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

សូមឧទ្ទិសបបួងសួងដល់ដួងវិញ្ញាណក្ខន្ធ លោកវរសេនីយ៍ត្រី អ៊ួន ហាច បានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។










# អ្នកឧកញ៉ា ប៊ុន ហៃ សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធវីរកងទ័ពពលីចំនួន ៥ រូបនៅខេត្តសៀមរាប



កាលពីថ្ងៃអាទិត្យ ទី៣ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ប៊ុន ហៃ សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធយោធិនពលី ៥រូបនៅខេត្តសៀមរាប ដែលមានដូចជា៖

១. ឧត្តមសេនីយ៍ត្រី ពៅ សំណាង យោធិននៃកងពលធំអន្តរាគន៍លេខ២ ដែលលោកបានពលីលើសមរភូមិក្នុងការការពារ និងវាយបកប្រឆាំងខ្មាំងសត្រូវឈ្លានពានទឹកដីនៅតំបន់ភ្នំទ្រព្យ ដោយពិធីបុណ្យរៀបចំឡើងនៅគេហដ្ឋានក្នុងភូមិសាលាក្រវ៉ាន់ ឃុំរំចេក ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

២. លោកព្រឹន្ទបាលឯក ឆាត ឈៀន ដែលបានពលីនៅសមរភូមិតំបន់ភ្នំទ្រព្យកាលថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥ ដោយពិធីបុណ្យរៀបចំឡើងនៅគេហដ្ឋានក្នុងភូមិព្រះដាក់ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

៣. លោកអនុសេនីយ៍ឯក អួត រ័ត្ន កងពលតូចអន្តរាគមន៍លេខ៤ ដែលបានពលីលើសមរភូមិក្នុងការការពារ និងវាយបកប្រឆាំងខ្មាំងសត្រូវឈ្លានពានទឹកដីនៅតំបន់ប្រាសាទតាមាន់ដោយពិធីបុណ្យរៀបចំឡើងនៅគេហដ្ឋានក្នុងភូមិបន្ទាយស្រី ឃុំខ្នាសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

៤. លោកអនុសេនីយ៍ត្រី ថន ញ៉ាញ់ ដែលបានពលីកាលថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥ តំបន់ភ្នំទ្រព្យដោយពិធីបុណ្យរៀបចំឡើងនៅគេហដ្ឋានក្នុង ភូមិរុនតាឯក ឃុំរុនតាឯក ក្រុងរុនតាឯក ខេត្តសៀមរាប។

៥. អនុសេនីយ៍ឯក គឹម សំអាត បម្រើការនៅកងពលធំអន្តរាគមន៍លេខ៣ ដែលលោកទទួលមរណភាព ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥ ក្នុងសរមភូមិមុខតំបន់ប្រាសាទព្រះវិហារ ដោយពិធីបុណ្យរៀបចំឡើងនៅគេហដ្ឋានស្ថិតក្នុងភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខ និងថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជាព្រមទាំងគ្រឿងឧបភោគបរិភោគមួយចំនួនទៀតជូនក្រុមគ្រួសារ នៃសពវីរជនទាំង ៥រូបផងដែរ។

មរណភាពរបស់យោធិនទាំង៥រូប គឺជាការបាត់បង់កូនប្រុសដ៏កត្តញ្ញូ បាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

















# លោកអ្នកឧកញ៉ា លាង យុន អនុប្រធាន និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធវីរកងទ័ពពលីចំនួន ៤ រូបនៅខេត្តសៀមរាប



កាលពីថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លាង យុន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដំណើរដោយអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងអ្នកឧកញ៉ា ឧកញ៉ា ជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាជាច្រើនរូបទៀតបានចូលរួមគោរពវិញ្ញាណក្ខន្ធយោធិនពលី ៤រូបនៅខេត្តសៀមរាបដែលមាននាមដូចជា៖

១. អនុសេនីយ៍ឯក អ៊ុន ឡាវហុង បម្រើការនៅកងពលតូចលេខ៨ កងពលធំអន្តរាគមន៍លេខ៣ ដែលបានពលីជីវិតនៅសមរភូមិព្រះវិហារ ក្នុងជន្មាយុ ៣៥ឆ្នាំ ដោយពិធីបុណ្យធ្វើឡើងនៅគេហដ្ឋានស្ថិតនៅពាម ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប។

២. ព្រិន្ទបាលឯក ថៃ លឹង បម្រើការនៅកងពលតូចលេខ៣ ចំណុះកងពលធំអន្តរាគមន៍លេខ៣ បានពលីក្នុងសមរភូមិតំបន់ភ្នំទ្រព្យ កាលពីថ្ងៃទី២៨ ខែកក្កដា ដោយពិធីបុណ្យធ្វើឡើងនៅគេហដ្ឋានស្ថិតនៅភូមិកាប់ដៃ ឃុំប្រាសាទ ស្រុកវ៉ារិន ខេត្តសៀមរាប។

៣.អនុសេនីយ៍ទោ ក្លែបរាយ មេបញ្ជាការរង គ១ កងពលតូចថ្មើរជើងលេខ៤២ យោធភូមិភាគទី៤ដែលបានពលីជីវិតក្នុងជន្មាយុ៥៥ឆ្នាំក្នុងសមរភូមិប្រាសាទតាមាន់កាលពីថ្ងៃទី២៤ ខែកក្កដា ដោយពិធីបុណ្យធ្វើឡើងនៅគេហដ្ឋានស្ថិតនៅភូមិធ្លក ឃុំត្រាំសសរ ស្រុកស្រីស្នំ ខេត្តសៀមរាប។

៤. អនុសេនីយ៍ឯក ឡោក ម៉ៅ បុគ្គលិក ខ២ គ១ វរសេនាតូចលេខ៤២៣ កងពលតូចថ្មើរជើងលេខ៤២ យោធភូមិភាគទី៤ ដែលបានពលីជីវិតក្នុងជន្មាយុ៤៨ឆ្នាំក្នុងសមរភូមិប្រាសាទតាមាន់ព្រឹកថ្ងៃទី២៤ខែកក្កដា ដោយពិធីបុណ្យធ្វើឡើងនៅគេហដ្ឋានស្ថិតនៅភូមិគោកព្រេច ឃុំត្រាំសសរ ស្រុកស្រីស្នំ ខេត្តសៀមរាប។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ លោកអ្នកឧកញ៉ា លាង យុន បាននាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខ និងថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជាព្រមទាំងគ្រឿងឧបភោគបរិភោគមួយចំនួនទៀតជូនក្រុមគ្រួសារនៃសពវីរជនទាំង ៤រូបផងដែរ។

មរណភាពរបស់យោធិនទាំង ៤រូបគឺជាការបាត់បង់កូនប្រុសដ៏កតញ្ញូ បាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។

វីរភាពនេះនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។














# លោកអ្នកឧកញ៉ា លាង ឃុន អនុប្រធាន និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរព វិញ្ញាណក្ខន្ធវីរកងទ័ពពលីចំនួន ៣ រូបនៅខេត្តបាត់ដំបង



កាលពីថ្ងៃចន្ទ ទី៤ ខែសីហា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លាង ឃុន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដំណើរដោយអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងអ្នកឧកញ៉ា ជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាជាច្រើនរូបទៀតបានបន្តចូលរួមគោរពវិញ្ញាណក្ខន្ធយោធិនពលី ៣រូបនៅខេត្តបាត់ដំបងដែលមាននាមដូចជា៖

១. លោកនាយចំណាង់ ឈឿង ចាន់ណា បម្រើការនៅវរសេនាតូចអន្តរាគមន៍៣៨២ កងពលតូចអន្តរាគមន៍លេខ៨ដែលលោកបានពលីជីវិតក្នុងសមរភូមិកាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ ដោយពិធីបុណ្យប្រារព្វឡើងនៅគេហដ្ឋានសពស្ថិតក្នុងឃុំខ្នាចរមាស ស្រុកបវេល ខេត្តបាត់ដំបង។

២.លោកនាយចំណាង់ មៀច សុខណាវាធីប នៃវរៈសេនាតូចថ្មើរជើង លេខ៤៤៤ ដែលបានពលីជីវិតកាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០២៥ ដោយពិធីបុណ្យធ្វើឡើងនៅគេហដ្ឋានស្ថិតក្នុងភូមិអូរគគី ឃុំអូររដា ស្រុកកំរៀង ខេត្តបាត់ដំបង។

៣. លោកនាយចំណាង់ ទេព ម៉ាឡា ជាយុទ្ធជនទ័ពពិសេសឆ័ត្រយោងកងពល៩១១ ដែលបានពលីជីវិតលើសមរភូមិភ្នំទ្រព្យកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥ ដោយពិធីបុណ្យធ្វើឡើងនៅគេហដ្ឋានស្ថិតក្នុងភូមិបោះពោធិ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង។

ក្នុងវេលាដ៏ក្រៀមក្រំនេះ លោកអ្នកឧកញ៉ា លាង ឃុន បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខ និងថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជាព្រមទាំងគ្រឿងឧបភោគបរិភោគមួយចំនួនទៀតជូនក្រុមគ្រួសារនៃសពវីរជនទាំង ៣រូបផងដែរ។

មរណភាពរបស់យោធិនទាំង ៣រូបគឺជាការបាត់បង់កូនប្រុសដ៏កត្តញ្ញូ បាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបានហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

សូមឧទ្ទិសបបួងសួងដល់ដួងវិញ្ញាណក្ខន្ធវីរជនទាំង ៣រូបសូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។














# អ្នកឧកញ៉ា សំ សុខនឿន និងឧកញ៉ាបណ្ឌិត លី រិទ្ធ តំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ចូលរួមគោរពវិញ្ញាណក្ខន្ធវីរកងទ័ពពលីចំនួន ៥រូប នៅខេត្តកំពង់ចាម ត្បូងឃ្មុំ និងស្ទឹងត្រែង







នាថ្ងៃចន្ទ ទី៤ និងថ្ងៃអង្គារ ទី៥ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ាបណ្ឌិត សំ សុខនឿន និងឧកញ៉ាបណ្ឌិត លី រិទ្ធ ចូលរួមជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានចូលរួមគោរពវិញ្ញាណក្ខន្ធយោធិនពលី ៥រូបនៅខេត្តកំពង់ចាម ត្បូងឃ្មុំ និងស្ទឹងត្រែងដែលមាននាមដូចជា៖

១. លោកអនុសេនីយ៍ឯក សៀង សាត ដែលបានពលីជីវិតក្នុងការការពារបូរណភាពជាតិ និងអធិបតេយ្យជាតិនៅតំបន់មុំ៣ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥ ដោយពិធីបុណ្យប្រារព្ធនៅភូមិស្រែប្រាំង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម។

២. លោកអនុសេនីយ៍ត្រី ភាព សោភ័ណ យោធិននៃបញ្ជាការដ្ឋានយោធភូមិភាគទី២ កងទ័ពជើងគោក ដែលលោកបានពលីជីវិតក្នុងបុព្វហេតុការពារជាតិមាតុភូមិនៅចំណុចតំបន់ប្រាសាទតាក្របី ដោយពិធីបុណ្យប្រារព្ធនៅភូមិបែកអន្លូងទី២ ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

៣. លោកព្រិន្ទបាលទោ ឆៃ រ័ត្ន នាយទាហានកងពលតូចអន្តរាគមន៍លេខ៩ វីរសេនាតូចអន្តរាគមន៍លេខ៣៩៤ ដែលបានពលីជីវិតក្នុងជន្មាយុ៤៧ឆ្នាំក្នុងបុព្វហេតុការពារបូរណភាពទឹកដីនៅលើសមរភូមិប្រយុទ្ធស្ថិតក្នុងខេត្តព្រះវិហារដោយពិធីបុណ្យប្រារព្ធនៅភូមិក្តុលកណ្តាល ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។

៤. លោកអនុសេនីយ៍ឯក អ៊ុត វណ្ណា ដែលបានពលីក្នុងបុព្វហេតុការពារជាតិមាតុភូមិវាយបកប្រឆាំងទប់ទល់នឹងកងកម្លាំងថៃឈ្លានពាន នៅចំណុចតំបន់ប្រាសាទតាក្របី ដោយពិធីបុណ្យប្រារព្ធនៅភូមិបុរីតេជោសែនកើត ឃុំដា ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

៥. លោកពលបាលឯក ស៊ីថា រិទ្ធី យុទ្ធជននៃវរសេនាតូចអន្តរាគមន៍២៨២ កងពលអន្តរាគមន៍លេខ១២៨ យោធភូមិភាគទី១ ដែលបានពលីនៅសមរភូមិបុស្សូរ-ជាំតែ ដោយពិធីបុណ្យប្រារព្ធនៅភូមិកណ្តាល ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

ជាមួយគ្នានេះ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ក៏ទទួលបានការស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់ឯកឧត្ដម ប៉ែន កុសល្យ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ ឯកឧត្ដម ខ្លូត ចិន្ដា អភិបាលរងខេត្តកំពង់ចាម ក៏ដូចជាឯកឧត្ដម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងអាជ្ញាធរមូលដ្ឋានក្នុងខេត្តកំពង់ចាម ត្បូងឃ្មុំ និងស្ទឹងត្រែងផងដែរ។

ក្នុងវេលាដ៏ក្រៀមក្រំនេះ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខ និងថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជាព្រមទាំងគ្រឿងឧបភោគបរិភោគមួយចំនួនទៀតជូនក្រុមគ្រួសារ នៃសពវីរជនទាំង ៥រូប។

មរណភាពរបស់យោធិនទាំង ៥រូបគឺជាការបាត់បង់កូនប្រុសដ៏កត្តញ្ញូ បាត់បង់ស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្ដុង្គឧត្ដមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពរបស់លោកនឹងស្ថិតក្នុងការចងចាំនៃដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបាន ហើយកេរ្តិ៍ឈ្មោះរបស់លោកនឹងត្រូវបានចារទុកនៅក្នុងប្រវត្តិសាស្ត្រជាតិ។

សូមឧទ្ទិសបបួងសួងដល់ដួងវិញ្ញាណក្ខន្ធវីរជនទាំង ៥រូបសូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។











# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល សិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ (ក.ផ.ផ.) លើកទី៦ ក្រោមអធិបតីភាព ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍















នារសៀលថ្ងៃអង្គារ ៤កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ តំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចូលរួម "កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ក.ផ.ផ) លើកទី៦" ដោយប្រារព្ធធ្វើឡើងនៅសណ្ឋាគារ រ៉ូសវូដភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដែលមានវត្តមានអញ្ជើញចូលរួមដោយ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា និងឧកញ៉ា ជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ក.ផ.ផ មកពីក្រសួងស្ថាប័ន សភាពាណិជ្ជកម្ម និងសមាគមពាក់ព័ន្ធ។

កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងដើម្បីពិនិត្យវឌ្ឍនភាព និងលទ្ធផលការងាររបស់ ក.ផ.ផ ឆមាសទី១ ឆ្នាំ២០២៥ និងដាក់ចេញនូវវិធានការគន្លឹះ និងផែនការយុទ្ធសាស្ត្រសម្រាប់ឆមាសទី២ ឆ្នាំ២០២៥ និងឆ្នាំ២០២៦ ជាពិសេសការដាក់ចេញនូវការផែនការចំពោះមុខសំដៅធានាភាពធន់នៃវិស័យទេសចរណ៍កម្ពុជា។

អង្គប្រជុំបានពិភាក្សា ផ្តល់ធាតុចូល និងសម្រេចលើរបៀបវារៈសំខាន់ៗរួមមាន ១.របាយការណ៍លទ្ធផលស្តីពីការផ្ទេរការងារពីអតីតអង្គភាពប្រតិបត្តិ ក.ផ.ផ ២.របាយការណ៍វឌ្ឍនភាពការងារសម្រាប់ត្រីមាសទី២ ឆ្នាំ២០២៥ និង ៣.របាយការណ៍ស្តីពីគោលដៅ និងផែនការសកម្មភាព ឆ្នាំ២០២៥-២០២៦។

កិច្ចប្រជុំបានបញ្ចប់ក្នុងកាលបរិច្ឆេទដដែលប្រកបដោយភាពរលូននិងលទ្ធផលផ្លែផ្កា ក្រោមបរិយាកាសស្និទ្ធស្នាល និងកក់ក្តៅ។

# អ្នកឧកញ៉ា សៀ ឬទ្ធី ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួម ជំនួបពិភាក្សាការងារអំពីការរៀបចំដំណើរបេសកកម្មទាក់ទាញ និងវិនិយោគនៅ ប្រទេសអូស្ត្រាលីក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល




នាព្រឹកថ្ងៃពុធ ១២កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ព្រមទាំងអ្នកឧកញ៉ា លី សុភាព និងឧកញ៉ា សូ សុខប៊ុនលីម បានចូលរួម "ជំនួបពិភាក្សាការងារអំពីការរៀបចំដំណើរបេសកកម្មទាក់ទាញ និងជំរុញវិនិយោគនៅប្រទេសអូស្ត្រាលី (Investment Roadshow to Australia)" នៅចុងខែសីហា ឆ្នាំ២០២៥ ខាងមុខនេះ ក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ឯកឧត្តម Derik Yip ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាព នៃប្រទេសអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាគមឧកញ៉ាកម្ពុជាដែលនឹងចូលរួមអមដំណើរឯកឧត្តមឧបនាយករដ្ឋមន្ត្រីនៅក្នុងដំណើរបេសកកម្មនេះផងដែរ។

គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីពិភាក្សាលើកិច្ចការអាទិភាពនានាក្នុងការត្រៀមរៀបចំដំណើរបេសកកម្មនេះឱ្យដំណើរការទៅបានប្រកបដោយភាពរលូន ប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់តាមការរំពឹងទុក។ សូមជម្រាបថា សមាគមឧកញ៉ាកម្ពុជា នឹងបញ្ជូនគណៈប្រតិភូចូលរួមក្នុងបេសកកម្មនេះផងដែរដើម្បីរួមចំណែកក្នុងការផ្សព្វផ្សាយ និងទាក់ទាញធុរជនអូស្ត្រាលីមកវិនិយោគនៅកម្ពុជាក៏ដូចជាស្វែងយល់អំពីបរិយាកាសធុរកិច្ចកម្ពុជា-អូស្ត្រាលី និងស្វែងរកដៃគូវិនិយោគលើវិស័យអាទិភាពនានា។ ដំណើរបេសកកម្មនេះ គឺជាសកម្មភាពទាក់ទាញ និងជំរុញវិនិយោគនៅក្រៅប្រទេសដែល ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សំដៅផ្សព្វផ្សាយពីបច្ចុប្បន្នភាពនៃបរិយាកាសវិនិយោគ និងសក្តានុពលនានារបស់កម្ពុជា និងបញ្ជ្រាបការយល់ដឹងដល់វិនិយោគិនបរទេសឱ្យមកបណ្តាក់ទុនវិនិយោគដោយផ្ទាល់ពីបរទេស (Foreign Direct Investment - FDI ) មកកាន់ប្រទេសកម្ពុជាថែមមួយកម្រិតទៀត។

ចំពោះបេសកកម្មទាក់ទាញនិងជំរុញវិនិយោគនៅប្រទេសអូស្ត្រាលីខាងមុខនេះបានទទួលនូវការសម្របសម្រួលដោយការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា និងកម្មវិធីភាពជាដៃគូកម្ពុជា- អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED)។





















# អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខវីរកងទ័ព ដែលរងរបួសនៅសមរភូមិនិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលា







នាព្រឹកថ្ងៃសុក្រ ទី៨ ខែសីហា ឆ្នាំ២០១៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលរួមមានវត្តមាន អ្នកឧកញ៉ា និងឧកញ៉ា ជាច្រើនរូបចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលា ក្រោមការយកចិត្តទុកដាក់ជាពិសេសពីថ្នាក់ដឹកនាំមន្ទីរពេទ្យ សាស្ត្រាចារ្យ និងវេជ្ជបណ្ឌិតឯកទេសគ្រប់ជំនាញផងដែរ។

ក្នុងឱកាសនេះដែរអ្នកឧកញ៉ាអគ្គលេខាធិការ បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខ និងការកោតសរសើរពីលោកអ្នកឧកញ៉ាប្រធាន ជូនចំពោះវីរភាពកងទ័ពដែលបានតស៊ូ លះបង់សាច់ស្រស់ ឈាមស្រស់ ដើម្បីបុព្វហេតុការពារបូរណភាព និងសេចក្តីសុខសន្តិភាពជូនជាតិ និងប្រជាជនកម្ពុជាប្រកបដោយភាពអង់អាចក្លាហានជាទីបំផុត រួមទាំងបានប្រគល់ជូននូវថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជា ជូនដល់យោធិនដែលកំពុងសម្រាកព្យាបាលរបួសផងដែរ។

ជាមួយគ្នានេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ ក៏ដូចជា អ្នកឧកញ៉ា និងឧកញ៉ា ទាំងអស់ដែលបានចូលរួមក្នុងដំណើរចុះសួរសុខទុក្ខនេះ បានជូនពរដល់វីរកងទ័ពទាំងអស់ដែលកំពុងសម្រាកព្យាបាលរបួស សូមបានឆាប់ជាសះស្បើយដើម្បីវិលត្រលប់ទៅបំពេញការងារនាពេលដ៏ខ្លីខាងមុខ។ បន្ថែមពីលើនេះ អ្នកឧកញ៉ា និងគណៈប្រតិភូ ក៏បានសម្តែងនូវអំណរគុណចំពោះក្រុមគ្រូពេទ្យ និងបុគ្គលិកសុខាភិបាលទាំងអស់ដែលបានកំពុងបំពេញនាទីជាកងទ័ពអាវសជួរក្រោយដោយឈរលើសាមគ្គីភាពជាធ្លុងមួយយកចិត្តទុកដាក់មិនរាថយបម្រើការថែទាំព្យាបាលអ្នកជំងឺគ្រប់ស្ថានការណ៍ ប្រកបដោយវិជ្ជាជីវៈ និងសេចក្តីស្រឡាញ់អាណិតអាសូរ។

សូមបញ្ជាក់ផងដែរថា នាសប្តាហ៍កន្លងមក ថ្នាក់ដឹកនាំក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាក៏បានចុះសួរសុខទុក្ខព្រមទាំងនាំយកនូវអំណោយជាថវិកា គ្រឿងឧបភោគបរិភោគផ្សេងៗជូនដល់ក្រុមគ្រួសារយោធិនពលីក្នុងសមរភូមិនាមូលដ្ឋានផ្ទាល់ដែលស្ថិតនៅក្នុង រាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានាផងដែរ។












# អ្នកឧកញ៉ា គួន ធីតា ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចុះសួរសុខទុក្ខ វីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ និងគ្លីនិក Jeremiah's Hope Clinic









នាថ្ងៃសុក្រ ទី៨ ខែសីហា ឆ្នាំ២០១៥ អ្នកឧកញ៉ា គួន ធីតា សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលរួមមានវត្តមាន អ្នកឧកញ៉ា និងឧកញ៉ាជាច្រើនរូបចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ និងគ្លីនិក Jeremiah's Hope Clinic ក្រោមការយកចិត្តទុកដាក់ជាពិសេសពីថ្នាក់ដឹកនាំមន្ទីរពេទ្យ សាស្ត្រាចារ្យ និងវេជ្ជបណ្ឌិតឯកទេសគ្រប់ជំនាញផងដែរ។

ក្នុងឱកាសនេះដែរ អ្នកឧកញ៉ា បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខ និងការកោតសរសើរពីលោកអ្នកឧកញ៉ាប្រធាន ជូនចំពោះវីរភាពកងទ័ពដែលបានតស៊ូ លះបង់សាច់ស្រស់ ឈាមស្រស់ ដើម្បីបុព្វហេតុការពារបូរណភាព និងសេចក្តីសុខសន្តិភាពជូនជាតិ និងប្រជាជនកម្ពុជា ប្រកបដោយភាពអង់អាចក្លាហានជាទីបំផុតរួមទាំងបានប្រគល់ជូននូវថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជាជូនដល់យោធិនដែលកំពុងសម្រាកព្យាបាលរបួសផងដែរ។

ជាមួយគ្នានេះ អ្នកឧកញ៉ា គួន ធីតា ក៏ដូចជា អ្នកឧកញ៉ា និងឧកញ៉ា ទាំងអស់ដែលបានចូលរួមក្នុងដំណើរចុះសួរសុខទុក្ខនេះបានជូនពរដល់វីរកងទ័ពទាំងអស់ដែលកំពុងសម្រាកព្យាបាលរបួស សូមបានឆាប់ជាសះស្បើយដើម្បីវិលត្រលប់ទៅបំពេញការងារនាពេលដ៏ខ្លីខាងមុខ។














# អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប







កាលពីថ្ងៃសៅរ៍ ទី៩ ខែសីហា ឆ្នាំ២០១៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលរួមមានវត្តមាន អ្នកឧកញ៉ា តែ អ៊ីផៃ និងឧកញ៉ា ស៊ិន សុទ្ធី បានចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប។ ក្នុងឱកាសនេះដែរ គណៈប្រតិភូបានទទួលការស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់លោក សំកុល សុចិត្រា អភិបាលរងខេត្តខេត្តសៀមរាប តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម ប្រាក់ សោភ័ណ អភិបាល នៃគណៈអភិបាលខេត្តសៀមរាប និងលោកវេជ្ជបណ្ឌិត ប៉ែន ផលគុណ ប្រធានមន្ទីរពេទ្យបង្អែកខេត្ត។

អ្នកឧកញ៉ាអគ្គលេខាធិការ បានពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខ និងការកោតសរសើរពីលោកអ្នកឧកញ៉ាប្រធាន ជូនចំពោះវីរភាពកងទ័ពដែលពោរពេញដោយឆន្ទៈដ៏មោះមុតក្លាហានក្នុងការការពារជាតិ សាសនា ព្រះមហាក្សត្រ និងបូរណភាពទឹកដីពីសត្រូវឈ្លានពានព្រមទាំងបាននាំយកនូវថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជាជូនដល់យោធិនដែលកំពុងសម្រាកព្យាបាលរបួសផងដែរ។

ជាមួយគ្នានេះ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បានជូនពរដល់វីរកងទ័ពទាំងអស់ដែលកំពុងសម្រាកព្យាបាលរបួស សូមបានឆាប់ជាសះស្បើយដើម្បីវិលត្រលប់ទៅបំពេញការងារនាពេលដ៏ខ្លីខាងមុខ។ អ្នកឧកញ៉ា និងឧកញ៉ាទាំងអស់ក៏បានសម្ដែងនូវអំណរគុណចំពោះថ្នាក់ដឹកនាំមន្ទីរពេទ្យ ក៏ដូចជាក្រុមគ្រូពេទ្យ និងបុគ្គលិកសុខាភិបាលគ្រប់ៗរូប ដែលបានកំពុងបំពេញនាទីជាកងទ័ពអាវសជួរក្រោយដោយឈរលើសាមគ្គីភាពជាធ្លុងមួយយកចិត្តទុកដាក់មិនរាថយបម្រើការថែទាំព្យាបាលអ្នកជំងឺគ្រប់ស្ថានការណ៍ ប្រកបដោយវិជ្ជាជីវៈ និងសេចក្ដីស្រឡាញ់អាណិតអាសូរ។

សូមបញ្ជាក់ថា នាសប្ដាហ៍កន្លងមកថ្នាក់ដឹកនាំក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាក៏បានចុះសួរសុខទុក្ខព្រមទាំងនាំយកនូវអំណោយជាថវិកាគ្រឿងឧបភោគបរិភោគផ្សេងៗជូនដល់ក្រុមគ្រួសារយោធិនពលីក្នុងសមរភូមិនាមូលដ្ឋានផ្ទាល់ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានាផងដែរ។












# អ្នកឧកញ៉ា ហ៊ុន ឡាក់ បន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យភូមិភាគ៤ ក្នុងខេត្តសៀមរាប



អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានបន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យភូមិភាគ៤ កាលពីរសៀលថ្ងៃសៅរ៍ ទី៩ ខែសីហា ឆ្នាំ២០១៥ ដោយក្នុងដំណើរបំពេញបេសកកម្មនេះក៏មានការចូលរួមពីអ្នកឧកញ៉ា តែ អ៊ីផៃ និងឧកញ៉ា ស៊ិន សុទ្ធី ផងដែរ។ ក្នុងឱកាសនេះដែរ គណៈប្រតិភូបានទទួលការស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់លោក សំកុល សុចិត្រា អភិបាលរងខេត្ត តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម ប្រាក់ សោភ័ណ អភិបាល នៃគណៈអភិបាលខេត្តសៀមរាប និងលោកវរសេនីយ៍ឯកវេជ្ជបណ្ឌិត ហៅ ទិត្យប៊ុនរ៉ា នាយកមន្ទីរពេទ្យភូមិភាគ៤។

អ្នកឧកញ៉ា ហ៊ុន ឡាក់ បានថ្លែងថា ក្នុងស្មារតីខ្មែរតែមួយផ្សារភ្ជាប់រវាងសមរភូមិមុខ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា សូមកោតសរសើរចំពោះវីរភាពកងទ័ពគ្រប់ៗរូបដែលពោរពេញដោយឆន្ទៈដ៏មោះមុតក្លាហានបំផុតក្នុងការការពារជាតិ សាសនា ព្រះមហាក្សត្រ និងបូរណភាពទឹកដីដោយបានលះបង់សាច់ស្រស់ ឈាមស្រស់ប្រយុទ្ធប្ដូរផ្ដាច់តទល់នឹងសត្រូវឈ្លានពាន។ ជាមួយគ្នានេះ គណៈប្រតិភូក៏បាននាំយកនូវថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជាប្រគល់ជូនដល់យោធិនដែលកំពុងសម្រាកព្យាបាលរបួសនិងបានជូនពរដល់វីរកងទ័ពទាំងអស់ដែលកំពុងសម្រាកព្យាបាលរបួស សូមបានឆាប់ជាសះស្បើយដើម្បីវិលត្រលប់ទៅបំពេញការងារនាពេលដ៏ខ្លីខាងមុខ។

អ្នកឧកញ៉ានិងឧកញ៉ាទាំងអស់ក៏បានសម្ដែងនូវអំណរគុណចំពោះថ្នាក់ដឹកនាំមន្ទីរពេទ្យក៏ដូចជាក្រុមគ្រូពេទ្យនិងបុគ្គលិកសុខាភិបាលគ្រប់ៗរូបដែលបានកំពុងបំពេញនាទីជាកងទ័ពអាវសជួរក្រោយដោយឈរលើសាមគ្គីភាពជាធ្លុងមួយយកចិត្តទុកដាក់មិនរាថយបម្រើការថែទាំព្យាបាលអ្នកជំងឺគ្រប់ស្ថានការណ៍ប្រកបដោយវិជ្ជាជីវៈ និងសេចក្ដីស្រឡាញ់អាណិតអាសូរ។

សូមបញ្ជាក់ថា នាសប្ដាហ៍កន្លងមកថ្នាក់ដឹកនាំក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាក៏បានចុះសួរសុខទុក្ខព្រមទាំងនាំយកនូវអំណោយជាថវិកាគ្រឿងឧបភោគបរិភោគផ្សេងៗជូនដល់ក្រុមគ្រួសារយោធិនពលីក្នុងសមរភូមិនាមូលដ្ឋានផ្ទាល់ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានាផងដែរ។














# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បន្តចុះសួរសុខទុក្ខវីរកងទ័ព ដែលរងរបួសនៅសមរភូមិនិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តមិត្តភាព កម្ពុជា-ជប៉ុន មង្គលបូរី ក្នុងខេត្តបន្ទាយមានជ័យ




អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានបន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តមិត្តភាពកម្ពុជា-ជប៉ុន មង្គលបូរី ក្នុងខេត្តបន្ទាយមានជ័យកាលពីរសៀលថ្ងៃសៅរ៍ ទី៩ ខែសីហា ឆ្នាំ២០១៥ ដោយក្នុងដំណើរបំពេញបេសកកម្មនេះក៏មានការចូលរួមពីអ្នកឧកញ៉ា តែ អ៊ីផៃ និងឧកញ៉ា ស៊ិន សុទ្ធី ផងដែរ។ ក្នុងឱកាសនេះដែរ គណៈប្រតិភូបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់លោកវេជ្ជបណ្ឌិត ទុ បារាំង ប្រធានមន្ទីរពេទ្យខេត្តមិត្តភាពកម្ពុជា-ជប៉ុន មង្គលបូរី។

អ្នកឧកញ៉ាអគ្គលេខាធិការបានថ្លែងថា ក្នុងស្មារតីខ្មែរតែមួយផ្សារភ្ជាប់រវាងសមរភូមិមុខ និងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា សូមកោតសរសើរចំពោះវីរភាពកងទ័ពគ្រប់ៗរូបដែលពោរពេញដោយឆន្ទៈដ៏មោះមុតក្លាហានក្នុងការការពារបូរណភាពទឹកដីប្រយុទ្ធប្តូរផ្តាច់តទល់នឹងសត្រូវឈ្លានពាន។ ជាមួយគ្នានេះ គណៈប្រតិភូក៏បាននាំយកនូវថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជា ប្រគល់ជូនដល់យោធិនដែលកំពុងសម្រាកព្យាបាលរបួស និងបានជូនពរដល់វីរកងទ័ពទាំងអស់ដែលកំពុងសម្រាកព្យាបាលរបួស សូមបានឆាប់ជាសះស្បើយដើម្បីវិលត្រលប់ទៅបំពេញការងារនាពេលដ៏ខ្លីខាងមុខ។

គណៈប្រតិភូក៏បានសម្តែងនូវអំណរគុណចំពោះថ្នាក់ដឹកនាំមន្ទីរពេទ្យក៏ដូចជាក្រុមគ្រូពេទ្យនិងបុគ្គលិកសុខាភិបាលគ្រប់ៗរូបដែលបានកំពុងបំពេញបម្រើការថែទាំព្យាបាលអ្នកជំងឺគ្រប់ស្ថានការណ៍ ប្រកបដោយវិជ្ជាជីវៈ និងសេចក្តីស្រឡាញ់អាណិតអាសូរ។

សូមបញ្ជាក់ថា នាសប្តាហ៍កន្លងមកថ្នាក់ដឹកនាំក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាក៏បានចុះសួរសុខទុក្ខព្រមទាំងនាំយកនូវអំណោយជាថវិកាគ្រឿងឧបភោគបរិភោគផ្សេងៗជូនដល់ក្រុមគ្រួសារយោធិនពលីក្នុងសមរភូមិនាមូលដ្ឋានផ្ទាល់ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានាផងដែរ។














# អ្នកឧកញ៉ា ផៃ ហុកឈួន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យកងពលថ្មើរជើងលេខ៤២ ក្នុងខេត្តឧត្តរមានជ័យ




នាថ្ងៃអាទិត្យ ទី១០ ខែសីហា ឆ្នាំ២០១៥ អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលរួមមានវត្តមាន អ្នកឧកញ៉ា និងឧកញ៉ា ជាច្រើនរូបចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកងពលថ្មើជើងលេខ៤២ ដែលស្ថិតក្នុងខេត្តឧត្តរមានជ័យ។ ក្នុងឱកាសនេះដែរ ក៏មានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តមកិត្តិសង្គហបណ្ឌិត គន់ គីម ទេសរដ្ឋមន្ត្រី អនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយផងដែរ។

អ្នកឧកញ៉ា ផៃ ហុកឈួន បានថ្លែងថា ក្នុងមនោសញ្ចេតនាគោរពស្រឡាញ់ដ៏ជ្រាលជ្រៅចំពោះវីរកងទ័ពដែលបានលះបង់សាច់ស្រស់ឈាមស្រស់ដើម្បីបុព្វហេតុការពារបូរណភាព និងសេចក្តីសុខសន្តិភាពជូនជាតិ និងប្រជាជនកម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានមានប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខ និងសូមកោតសរសើរចំពោះវីរភាពដ៏អង់អាចក្លាហានរបស់យោធិនគ្រប់ៗរូប ព្រមទាំងបានជូនពរដល់វីរកងទ័ពទាំងអស់ដែលកំពុងសម្រាកព្យាបាលរបួស សូមបានឆាប់ជាសះស្បើយដើម្បីវិលត្រលប់ទៅបំពេញការងារនាពេលដ៏ខ្លីខាងមុខ។បន្ថែមពីលើនេះ គណៈប្រតិភូក៏បាននាំយកនូវថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជា ជូនដល់យោធិនដែលកំពុង សម្រាកព្យាបាលរបួសផងដែរ។

ទន្ទឹមនឹងនេះដែរ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បានសម្តែងនូវអំណរគុណចំពោះថ្នាក់ដឹកនាំមន្ទីរពេទ្យទាំងអស់ក៏ដូចជាក្រុមគ្រូពេទ្យ និងបុគ្គលិកសុខាភិបាលគ្រប់ផ្នែកដែលបានកំពុងបំពេញនាទីជាកងទ័ពអាវសជួរក្រោយដោយឈរលើសាមគ្គីភាពជាធ្លុងមួយយកចិត្តទុកដាក់មិនរាថយបម្រើការថៃទាំព្យាបាលអ្នកជំងឺគ្រប់ស្ថានការណ៍ប្រកបដោយវិជ្ជាជីវៈ និងសេចក្តីស្រឡាញ់អាណិតអាសូរ។

សូមបញ្ជាក់ថា នាសប្តាហ៍កន្លងមកថ្នាក់ដឹកនាំក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាក៏បានចុះសួរសុខទុក្ខព្រមទាំងនាំយកនូវអំណោយជាថវិកាគ្រឿងឧបភោគបរិភោគផ្សេងៗជូនដល់ក្រុមគ្រួសារយោធិនពលីក្នុងសមរភូមិនាមូលដ្ឋានផ្ទាល់ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានាផងដែរ។














# អ្នកឧកញ៉ា អ៊ាន អេឡៃន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាល នៅគិលានដ្ឋានតំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ




នាថ្ងៃអាទិត្យ ទី១០ ខែសីហា ឆ្នាំ២០១៥ អ្នកឧកញ៉ា អ៊ាន អេឡៃន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលរួមមានវត្តមាន អ្នកឧកញ៉ា និងឧកញ៉ា ជាច្រើនរូបចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅគិលានដ្ឋានតំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ។

ក្នុងឱកាសនេះ អ្នកឧកញ៉ាអនុប្រធាន បានថ្លែងថា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានមានប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខ និងសូមកោតសរសើរចំពោះវីរភាពដ៏អង់អាចក្លាហានរបស់យោធិនគ្រប់ៗរូប ព្រមទាំងបានជូនពរដល់វីរកងទ័ពទាំងអស់ដែលកំពុងសម្រាកព្យាបាលរបួស សូមបានឆាប់ជាសះស្បើយដើម្បីវិលត្រលប់ទៅបំពេញការងារនាពេលដ៏ខ្លីខាងមុខ។ បន្ថែមពីលើនេះ គណៈប្រតិភូក៏បាននាំយកនូវថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជា ជូនដល់យោធិនដែលកំពុងសម្រាកព្យាបាលរបួសផងដែរ។

ទន្ទឹមនឹងនេះ អ្នកឧកញ៉ា អ៊ាន អេឡៃន រួមទាំងគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បានសម្តែងនូវអំណរគុណចំពោះថ្នាក់ដឹកនាំមន្ទីរពេទ្យទាំងអស់ក៏ដូចជាក្រុមគ្រូពេទ្យនិងបុគ្គលិកសុខាភិបាលគ្រប់ផ្នែកដែលបានកំពុងបំពេញនាទីជាកងទ័ពអាវសជួរក្រោយដោយឈរលើសាមគ្គីភាពជាធ្លុងមួយយកចិត្តទុកដាក់មិនរាថយបម្រើការថែទាំព្យាបាលអ្នកជំងឺគ្រប់ស្ថានការណ៍ប្រកបដោយវិជ្ជាជីវៈ។

សូមបញ្ជាក់ថា នាសប្តាហ៍កន្លងមកថ្នាក់ដឹកនាំក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាក៏បានចុះសួរសុខទុក្ខព្រមទាំងនាំយកនូវអំណោយជាថវិកាគ្រឿងឧបភោគបរិភោគផ្សេងៗជូនដល់ក្រុមគ្រួសារយោធិនពលីក្នុងសមរភូមិនាមូលដ្ឋានផ្ទាល់ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានាផងដែរ។














# អ្នកឧកញ៉ា ទី គឹមស្រ៊ាន ដឹកនាំគណៈប្រតិភូ សមាគមឧកញ៉ាកម្ពុជាចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត











អ្នកឧកញ៉ា ទី គឹមស្រ៊ាន សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលរួមមានវត្តមាន អ្នកឧកញ៉ា និងឧកញ៉ា ជាច្រើនរូបចុះសួរសុខទុក្ខវីរកងទ័ពដែលរងរបួសនៅសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៥កន្លងទៅថ្មីៗនេះ។

ក្នុងឱកាសនេះដែរ អ្នកឧកញ៉ា ទី គឹមស្រ៊ាន បានពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខ និងការកោតសរសើរពីលោកអ្នកឧកញ៉ាប្រធាន ជូនចំពោះវីរភាពកងទ័ពដែលបានតស៊ូ លះបង់សាច់ស្រស់ ឈាមស្រស់ ដើម្បីបុព្វហេតុការពារបូរណភាព និងសេចក្ដីសុខសន្តិភាពជូនជាតិ និងប្រជាជនកម្ពុជាប្រកបដោយភាពអង់អាចក្លាហានជាទីបំផុតរួមទាំងបានប្រគល់ជូននូវថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជា ជូនដល់យោធិនដែលកំពុងសម្រាកព្យាបាលរបួសផងដែរ។

ជាមួយគ្នានេះ គណៈប្រតិភូក៏បានជូនពរដល់វីរកងទ័ពទាំងអស់ដែលកំពុងសម្រាកព្យាបាលរបួស សូមបានឆាប់ជាសះស្បើយដើម្បីវិលត្រលប់ទៅបំពេញការងារនាពេលដ៏ខ្លីខាងមុខ និងបានសម្ដែងនូវអំណរគុណចំពោះក្រុមគ្រូពេទ្យ និងបុគ្គលិកសុខាភិបាលទាំងអស់ ដែលបានកំពុងបំពេញនាទីជាកងទ័ពអាវសជួរក្រោយដោយឈរលើសាមគ្គីភាពជាធ្លុងមួយយកចិត្តទុកដាក់មិនរាថយបម្រើការថែទាំព្យាបាលអ្នកជំងឺគ្រប់ស្ថានការណ៍ ប្រកបដោយវិជ្ជាជីវៈ និងសេចក្តីស្រឡាញ់អាណិតអាសូរ។

សូមបញ្ជាក់ថា នាសប្តាហ៍កន្លងមកថ្នាក់ដឹកនាំក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាក៏បានចុះសួរសុខទុក្ខព្រមទាំងនាំយកនូវអំណោយជាថវិកាគ្រឿងឧបភោគបរិភោគផ្សេងៗជូនដល់ក្រុមគ្រួសារយោធិនពលីក្នុងសមរភូមិនាមូលដ្ឋានផ្ទាល់ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានាផងដែរ។

























# អ្នកឧកញ៉ា អ៊ាន អេឡៃន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរព វិញ្ញាណក្ខន្ធសពយុទ្ធជនពលី លោកអនុសេនីយ៍ឯក ញឹក ប៊ុនសោន នៅខេត្តស្វាយរៀង

នាថ្ងៃចន្ទ ទី១៨ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា អ៊ាន អេឡៃន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពលោកអនុសេនីយ៍ឯក ញឹក ប៊ុនសោន ដែលបានពលីក្នុងសមរភូមិភ្នំទ្រព្យដើម្បីការពារជាតិមាតុភូមិក្នុងការវាយបកប្រឆាំងទាហានសៀមឈ្លានពានដោយពិធីបុណ្យបានប្រារព្ធធ្វើនៅគេហដ្ឋានស្ថិតនៅក្នុងខេត្តស្វាយរៀង។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា អ៊ាន អេឡៃន បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធានក៏ដូចជាលិខិតរំលែកមរណទុក្ខ និងថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជាជូនក្រុមគ្រួសារ នៃសពផងដែរ។

មរណភាពរបស់លោកអនុសេនីយ៍ឯក ញឹក ប៊ុនសោន គឺជាការបាត់បង់នូវស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនៗហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពដ៏អង់អាចរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបាន។

សូមឧទ្ទិសបបួងសួងដល់ដួងវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ឯក ញឹក ប៊ុនសោន បានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។















# អ្នកឧកញ៉ា ផៃ ហុកឈួន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខ និងនាំយកអំណោយជាថវិកាប្រគល់ជូនវីរយុទ្ធជនដែលរបួស និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យចំនួន ២ក្នុងខេត្តព្រះវិហារ

នាព្រឹកថ្ងៃអង្គារ ទី១៩ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដោយអ្នកឧកញ៉ាអគ្គលេខាធិការ និងអ្នកឧកញ៉ាសមាជិកក្រុមប្រឹក្សាភិបាលជាច្រើនរូបបានចុះសួរសុខទុក្ខ និងនាំយកអំណោយជាថវិកាប្រគល់ជូនវីរយុទ្ធជនដែលបានរបួសក្នុងសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែក ១៦មករា និងមណ្ឌលសុខភាពគូលែនដែលស្ថិតក្នុងខេត្តព្រះវិហារ។

ក្នុងឱកាសនេះដែរគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បានទទួលការស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់ឯកឧត្តម មិន ស៊ីថា អភិបាលរងខេត្ត និងជាតំណាងឯកឧត្តម គីម រិទ្ធី អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ រួមទាំងលោកវេជ្ជបណ្ឌិត ជូ ប៊ុនីណា ប្រធានមន្ទីរពេទ្យបង្អែក១៦មករា និងលោក ទិត្យ សារុំ ប្រធានមណ្ឌលសុខភាពគូលែនផងដែរ។

សូមបញ្ជាក់ថា នាពេលកន្លងមកគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បាននាំយកនូវអំណោយជាថវិកាមួយចំនួនក៏ដូចជាគ្រឿងឧបភោគបរិភោគផ្សេងៗដើម្បីប្រគល់ជូនវីរយុទ្ធជនដែលបានរងរបួស និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រមទាំងក្រុមគ្រួសារវីរជនពលីផងដែរ។
















A37




A35
G 09



14

19



សកម្មភាពរបស់គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាដឹកនាំដោយអ្នកឧកញ៉ា ផៃ ហុកឈួន ជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដោយអ្នកឧកញ៉ាអគ្គលេខាធិការ និងអ្នកឧកញ៉ាសមាជិកក្រុមប្រឹក្សាភិបាលជាច្រើនរូបបានចុះសួរសុខទុក្ខ និងនាំយកអំណោយជាថវិកាប្រគល់ជូនវីរយុទ្ធជនដែលបានរបួសក្នុងសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាពគូលែនដែលស្ថិតក្នុងខេត្តព្រះវិហារ។

























# អ្នកឧកញ៉ា ផៃ ហុកឈួន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរព វិញ្ញាណក្ខន្ធសពវីរយុទ្ធជនដែលបានពលីក្នុងសមរភូមិចំនួន ២រូបក្នុងខេត្តព្រះវិហារ









នាថ្ងៃអង្គារ ទី១៩ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាអមដោយអ្នកឧកញ៉ាអគ្គលេខាធិការ និងអ្នកឧកញ៉ាសមាជិកក្រុមប្រឹក្សាភិបាលជាច្រើនរូបបានចុះសួរសុខទុក្ខក៏ដូចជានាំយកអំណោយជាថវិកាប្រគល់ជូនក្រុមគ្រួសារវីរយុទ្ធជនដែលបានពលីក្នុងសមរភូមិចំនួន ២រូបក្នុងខេត្តព្រះវិហារ។

ក្នុងឱកាសនេះដែរក៏មានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម មិន ស៊ីថា អភិបាលរងខេត្ត និងជាតំណាងឯកឧត្តម គីម រិទ្ធី អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ រួមទាំងថ្នាក់ដឹកនាំខេត្តអាជ្ញាធរមូលដ្ឋានផងដែរ។

សូមបញ្ជាក់ថា គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បាននាំយកថវិកាជូនក្រុមគ្រួសារវីរយោធិនពលីទាំង ២រូបរួមមាន៖

១. លោកវរសេនីយ៍ទោ រឿម តុងសៀន ដែលបានពលីជីវិតនៅសមរភូមិជួរមុខខេត្តឧត្តរមានជ័យ ខណៈដែលក្រុមគ្រួសារកំពុងស្នាក់នៅជាបណ្តោះអាសន្ននៅជុំរុំភៀសសឹកវត្តពោធិ៍ព្រឹក្ស៥០០០ដើម។

២. លោកវរសេនីយ៍ត្រី សូត្រ ពេជ្រ ដែលបានពលីជីវិតនៅសមរភូមិមុខភ្នំទ្រព្យ ខណៈដែលក្រុមគ្រួសារកំពុងស្នាក់នៅជាបណ្តោះអាសន្ននៅជុំរុំភៀសសឹកវត្តសាលវន្តរង្សី ហៅវត្តស្រយង់កោះកេរ។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធវីរជនពលីទាំង ២រូបបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

# អ្នកឧកញ៉ា ផៃ ហុកឈួន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធសពលោកវរសេនីយ៍ត្រី ប៊ូ ផូ ស្ថិតនៅខេត្តកំពង់ធំ









នាថ្ងៃពុធ ទី២០ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដោយអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងអ្នកឧកញ៉ាសមាជិកក្រុមប្រឹក្សាភិបាលជាច្រើនរូបបានចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពលោកវរសេនីយ៍ត្រី ប៊ូ ផូ ជាយោធិនក្នុងកងពលតូចអន្តរាគមន៍លេខ៨ នៃកងពលធំអន្តរាគមន៍លេខ៣ កងទ័ពជើងគោក ដែលបានពលីក្នុងសមរភូមិដើម្បីបុព្វហេតុការពារជាតិមាតុភូមិដោយពិធីបុណ្យត្រូវបានប្រារព្ធឡើងនៅគេហដ្ឋានក្នុងភូមិវាលតូច ឃុំអណ្តូងពោធិ៍ ស្រុកតាំងគោក ខេត្តកំពង់ធំ។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា ផៃ ហុកឈួន បានពាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខ និងថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជាជូនក្រុមគ្រួសារ នៃសពផងដែរ។

មរណភាពរបស់លោកវរសេនីយ៍ត្រី ប៊ូ ផូ គឺជាការបាត់បង់នូវស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា ជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនៗហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពដ៏អង់អាចរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបាន។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធលោកវរសេនីយ៍ត្រី ប៊ូ ផូ បានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ រួមជាមួយសមាជិកសមាគមឧកញ៉ាកម្ពុជា ចូលរួមជំនួបពិភាក្សាជាមួយលោក គី សុខគីម នាយកប្រតិបត្តិមូលនិធិអភិវឌ្ឍន៍ជំនាញ



នាថ្ងៃព្រហស្បតិ៍ ទី២១ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលមានសមាសភាពអ្នកឧកញ៉ា និងឧកញ៉ា ជាសមាជិកក្រុមប្រឹក្សាភិបាល និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជាជាច្រើនរូប ចូលរួមក្នុងជំនួបពិភាក្សាជាមួយលោក គី សុខគីម នាយកប្រតិបត្តិមូលនិធិអភិវឌ្ឍន៍ជំនាញក្នុងគោលបំណងស្វែងយល់ពីបញ្ហាប្រឈម និងតម្រូវការនៃការផ្គត់ផ្គង់ពីសហគ្រាសធុនតូច និងមធ្យម (SMEs) សម្រាប់គាំទ្រដល់ខ្សែច្រវាក់ផលិតកម្មនៃសហគ្រាសធុនធំរបស់សមាជិក នៃសមាគមឧកញ៉ាកម្ពុជា។

ក្នុងឱកាសនោះដែរ ថ្នាក់ដឹកនាំ នៃមូលនិធិអភិវឌ្ឍន៍ជំនាញ (Skills Development Fund ឬ SDF) បានណែនាំជូនប្រតិភូសមាគមឧកញ៉ាកម្ពុជា នូវកម្មវិធីថ្មី (Queen Bee) របស់ SDF ដែលមានទិសដៅជួយដោះស្រាយបញ្ហាជាកញ្ចប់ក្នុងខ្សែច្រវាក់ផលិតកម្មទាំងមូលជាពិសេសផ្តល់ការគាំទ្រដល់ការលើកកម្ពស់សមត្ថភាពធនធានមនុស្សឱ្យមានជំនាញច្បាស់លាស់ដើម្បីចូលរួមគាំទ្រដល់ការពង្រីកផលិតកម្មក្នុងស្រុកឱ្យកាន់តែប្រសើរឡើង។

ជាលទ្ធផល SDF និងសមាគមឧកញ៉ាកម្ពុជា បានឯកភាពលើជំហានបន្ទាប់ដូចខាងក្រោម៖

១) SDF និងសមាគមឧកញ៉ាកម្ពុជា នឹងសហការគ្នារៀបចំសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីគាំទ្រនានារបស់ SDF និងជាពិសេសកម្មវិធី ( Queen Bee) ដែលកំពុងរៀបចំ និងគ្រោងដាក់ដំណើរការនាពេលឆាប់ៗខាងមុខ។

២) SDF និងសមាគមឧកញ៉ាកម្ពុជា នឹងសហការគ្នា ជំរុញការគាំទ្រផលិតកម្មដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុកដើម្បីពង្រឹង និងពង្រីកខ្សែច្រវាក់ផលិតកម្មកម្ពុជាទាំងបរិមាណ និងគុណភាព។

៣) SDF និងគាំទ្រដល់ការអភិវឌ្ឍជំនាញ និងបង្កើនសមត្ថភាពធនធានមនុស្សដល់ម្ចាស់សហគ្រាសដែលជាសមាជិករបស់សមាគមឧកញ៉ាកម្ពុជាដើម្បីបង្កើនប្រសិទ្ធភាពការងារ គុណភាព និងផលិតភាព។

តាមរយៈជំនួបដ៏មានសារៈសំខាន់នេះ SDF នឹងជំរុញការផ្សារភ្ជាប់ជាមួយសមាគមឧកញ៉ាកម្ពុជាដែលជាបណ្តុំធុរជនកំពុងប្រកបអាជីវកម្ម និងដឹកនាំទាំងសហគ្រាសធុនតូច និងមធ្យម ក៏ដូចជាក្រុមហ៊ុនធំៗ (industry leaders) តាមរយៈកម្មវិធីថ្មីដែលផ្តល់ដំណោះស្រាយជាកញ្ចប់ ដើម្បីពង្រឹង និងពង្រីកខ្សែច្រវាក់ក់ផលិតកម្មស្របតាមស្តង់ដា និងអាចពង្រីកផលិតកម្មក្នុងស្រុកឱ្យកាន់តែប្រសើរឡើង។















## អ្នកឧកញ៉ា ឡាវ កាង ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខនិងប្រគល់អំណោយជាម៉ូតូ កង្ហារ ជូនមន្ទីរពេទ្យកងពលថ្មើរជើងលេខ៤២ ក្នុងខេត្តឧត្តរមានជ័យ និងថវិកាជូនបុគ្គលិកសុខាភិបាលនៅទីនោះផងដែរ








នាថ្ងៃសៅរ៍ ទី២៣ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ឡាវ កាង សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលរួមមានវត្តមាន អ្នកឧកញ៉ា និងឧកញ៉ា ជាច្រើនរូបចុះសួរសុខទុក្ខ ក៏ដូចជានាំយកនូវអំណោយជាម៉ូតូចំនួន ៥គ្រឿង និងកង្ហារដើម្បីប្រគល់ជូនមន្ទីរពេទ្យកងពលថ្មើជើងលេខ៤២ ក្នុងខេត្តឧត្តរមានជ័យ សម្រាប់ប្រើប្រាស់តាមតម្រូវការព្រមទាំងបានប្រគល់ជូនថវិកាមួយចំនួនដល់បុគ្គលិកសុខាភិបាលដែលកំពុងបម្រើការនៅទីនោះផងដែរ។

ក្នុងឱកាសនេះដែរ អ្នកឧកញ៉ា ឡាវ កាង រួមទាំងគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បានសម្តែងនូវអំណរគុណចំពោះថ្នាក់ដឹកនាំមន្ទីរពេទ្យទាំងអស់ ក៏ដូចជាក្រុមគ្រូពេទ្យ និងបុគ្គលិកសុខាភិបាលគ្រប់ផ្នែក ដែលបានកំពុងបំពេញនាទីជាកងទ័ពអាវសជួរក្រោយដោយឈរលើសាមគ្គីភាពជាធ្លុងមួយយកចិត្តទុកដាក់មិនរាថយបម្រើការថែទាំព្យាបាលអ្នកជំងឺជាពិសេសវីរកងទ័ពដែលបានរងរបួសក្នុងសមរភូមិប្រយុទ្ធតទល់និងបរទេសឈ្លានពានប្រកបដោយវិជ្ជាជីវៈខ្ពស់។

សូមបញ្ជាក់ថា នាសប្តាហ៍កន្លងមកថ្នាក់ដឹកនាំ ក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាក៏បានចុះសួរសុខទុក្ខព្រមទាំងនាំយកនូវអំណោយជាថវិកា ជូនដល់វីរយុទ្ធជនដែលបានរងរបួស និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកងពលថ្មើជើងលេខ៤២ ក្នុងខេត្តឧត្តរមានជ័យនេះផងដែរ ហើយដោយបានមើលឃើញនូវការលំបាក និងកង្វះខាតសម្ភារៈទើបសមាគមបានសម្រេចផ្តល់ជូនបន្ថែមទៀតនូវម៉ូតូ និងកង្ហារនាពេលនេះតែម្តង។














# អ្នកឧកញ៉ា ឡាវ កាង ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខ និងនាំយកអំណោយ ជាថវិកាជូនវីរកងទ័ពដែលបានរបួសក្នុងសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ













នាថ្ងៃសៅរ៍ ទី២៣ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ឡាវ កាង សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលរួមមានវត្តមាន អ្នកឧកញ៉ា និងឧកញ៉ា ជាច្រើនរូបចុះសួរសុខទុក្ខ និងនាំយកអំណោយជាថវិកាប្រគល់ជូនវីរយុទ្ធជនដែលបានរបួសក្នុងសមរភូមិ និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ។

ក្នុងឱកាសនេះដែរ អ្នកឧកញ៉ា ឡាវ កាង បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខ និងសូមកោតសរសើរចំពោះវីរភាពដ៏អង់អាចក្លាហានរបស់យោធិនគ្រប់ៗរូបពីលោកអ្នកឧកញ៉ាប្រធាន ព្រមទាំងបានជូនពរដល់វីរកងទ័ពទាំងអស់ដែលកំពុងសម្រាកព្យាបាលរបួស សូមបានឆាប់ជាសះស្បើយដើម្បីវិលត្រលប់ទៅបំពេញការងារនាពេលដ៏ខ្លីខាងមុខ។

ទន្ទឹមនឹងនេះ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា បានសម្តែងនូវអំណរគុណចំពោះថ្នាក់ដឹកនាំមន្ទីរពេទ្យទាំងអស់ ក៏ដូចជាក្រុមគ្រូពេទ្យ និងបុគ្គលិកសុខាភិបាលគ្រប់ផ្នែកដែលបានកំពុងបំពេញនាទីជាកងទ័ពអាវសជួរក្រោយដោយឈរលើសាមគ្គីភាពជាធ្លុងមួយយកចិត្តទុកដាក់ មិនរាថយបម្រើការថែទាំព្យាបាលអ្នកជំងឺគ្រប់ស្ថានការណ៍ប្រកបដោយវិជ្ជាជីវៈខ្ពស់។














# អ្នកឧកញ៉ា សៀ ឫទ្ធី ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគនៅប្រទេសអូស្ត្រាលី

យោងតាមសំណើពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា សៀ ឫទ្ធី អនុប្រធាន និងជាប្រធានគណៈកម្មការទំនាក់ទំនងសាធារណៈ និងអន្តរជាតិ ធ្វើជាតំណាងលោកអ្នកឧកញ៉ាប្រធាន ដើម្បីដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលមានសមាសភាពដូចជា៖ អ្នកឧកញ៉ា ហ៊ុន ឡាក់, អ្នកឧកញ៉ា គួន ធីតា, អ្នកឧកញ៉ា លី សុភាព, ឧកញ៉ា សូ សុខប៊ុនលីម និងឧកញ៉ា ម៉ៅ បញ្ញពណ៌ ចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគនៅប្រទេសអូស្ត្រាលីចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៥។











នាព្រឹកថ្ងៃចន្ទ ទី២៥ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញជួបពិភាក្សាការងារជាមួយប្រតិភូក្រុមហ៊ុន CIMIC Group ដឹកនាំដោយលោក Robert Seidler សមាជិកក្រុមប្រឹក្សាភិបាលក្រុមហ៊ុន CIMIC Group។ ជំនួបពិភាក្សានេះមានការចូលរួមពីគណៈប្រតិភូអមដំណើរមានជាអាទិ៍ ឯកឧត្តមឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់, ឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា, ព្រមទាំងថ្នាក់ដឹកនាំនៃក្រសួងស្ថាប័នរួមមានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ, ក្រសួងរ៉ែ និងថាមពល, ក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងសមាសភាពពីសមាគមឧកញ៉ាកម្ពុជាដែលដឹកនាំដោយអ្នកឧកញ៉ា សៀ ឫទ្ធី ផងដែរ។

ក្នុងឱកាសនៃជំនួបនេះ លោក Robert Seidler បានថ្លែងអំណរគុណជូនដល់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ដែលបានអនុញ្ញាតឱ្យប្រតិភូក្រុមហ៊ុនបានជួបសម្តែងការគួរសម និងធ្វើបច្ចុប្បន្នភាពពីសកម្មភាពអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ លោកក៏បានជម្រាបជូនអំពីវឌ្ឍនភាពនៃការវិនិយោគរបស់ខ្លួននៅកម្ពុជានិងផែនការពង្រីកការវិនិយោគបន្ថែមឈរលើមូលដ្ឋាននៃភាពជឿជាក់លើការដឹកនាំរបស់រាជរដ្ឋាភិបាល។ ក្រុមហ៊ុនក៏បានសម្តែងនូវការពេញចិត្តចំពោះការធ្វើឱ្យប្រសើរឡើងនូវបរិស្ថានវិនិយោគ ដែលបានបង្កនូវភាពងាយស្រួលក្នុងការបណ្តាក់ទុននិងការធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅកម្ពុជា។ ជាពិសេសជាងនេះកម្ពុជាមានកម្លាំងពលកម្មដែលមានឧត្តមភាពប្រកួតប្រជែងខ្ពស់ និងមានភាពស្វាហាប់ ព្រមទាំងងាយស្រួលក្នុងការទទួលយកការបណ្តុះបណ្តាលថ្មីៗផងដែរ។

# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបពិភាក្សាការងារជាមួយ នាយកប្រតិបត្តិទីភ្នាក់ងារឥណទានសម្រាប់ការនាំចេញរបស់រដ្ឋាភិបាលអូស្ត្រាលី







នាថ្ងៃចន្ទ ទី២៥ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា សៀ ឫទ្ធី បានបន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រីអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងជំនួបពិភាក្សាការងារជាមួយនាយកប្រតិបត្តិទីភ្នាក់ងារឥណទានសម្រាប់ការនាំចេញរបស់រដ្ឋាភិបាលអូស្ត្រាលី (Export Finance Australia – EFA) លោក John Hopkins។

នៅក្នុងជំនួបនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងអ្នកតំណាង EFA បានពិភាក្សាផ្លាស់ប្តូរយោបល់ ចែករំលែកបទពិសោធការងារទៅវិញទៅមកដោយក្នុងនោះតំណាង EFA បានជម្រាបជូនអំពីតួនាទី និងសេវាកម្មសំខាន់ៗរបស់ខ្លួនដែលរួមមានដូចជា៖ ការផ្តល់សេវាហិរញ្ញប្បទាន, ការបំពេញចន្លោះប្រហោងទីផ្សារ ក្នុងករណីដែលធនាគារពាណិជ្ជ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតមិនអាចផ្តល់ហិរញ្ញប្បទានបានគ្រប់គ្រាន់, ការគាំទ្រគម្រោងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយនិរន្តរភាព, និងការផ្តល់ការគាំទ្រដល់វិស័យផ្សេងៗ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានជម្រាបជូនផងដែរអំពីបច្ចុប្បន្នភាពនៃបរិយាកាសវិនិយោគនៅកម្ពុជាក៏ដូចជាសក្តានុពលនានាស័ក្តិសមសម្រាប់ការជ្រើសរើសជាគោលដៅវិនិយោគក្នុងបរិការណ៍ពិភពលោកនាពេលបច្ចុប្បន្ន ដោយបានសង្កត់ធ្ងន់លើទស្សនវិស័យប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ដែលចាត់ទុកវិស័យឯកជនជាដៃគូសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ និងបានដាក់ចេញនូវគោលនយោបាយ និងរៀបចំយុទ្ធសាស្ត្រជាអាទិភាពជាបន្តបន្ទាប់ ដើម្បីបន្តលើកកម្ពស់បរិយាកាសវិនិយោគ និងការធ្វើពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា។

សូមបញ្ជាក់ថា ទីភ្នាក់ងារឥណទានសម្រាប់ការនាំចេញរបស់រដ្ឋាភិបាលអូស្ត្រាលី (EFA) គឺជាស្ថាប័នដែលត្រូវបានបង្កើតឡើងដើម្បីគាំទ្រពាណិជ្ជកម្មនាំចេញរបស់អូស្ត្រាលី និងជួយដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនៅក្នុងប្រទេសជាដៃគូ។(EFA)មានគោលដៅជំរុញកំណើនប្រកបដោយនិរន្តរភាព ដែលផ្តល់អត្ថប្រយោជន៍ដល់ប្រទេសអូស្ត្រាលី និងប្រទេសជាដៃគូរបស់ខ្លួនតាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុ និងដំណោះស្រាយជំនាញបច្ចេកទេសផ្សេងៗដើម្បីលើកកម្ពស់ការវិនិយោគពីអូស្ត្រាលីនៅក្នុងប្រទេសជាដៃគូនោះឱ្យកាន់តែមានភាពប្រកួតប្រជែងខ្ពស់នៅក្នុងទីផ្សារអន្តរជាតិ។

# អ្នកឧកញ៉ា សៀ ឫទ្ធី ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបពិភាក្សាការងារ ជាមួយតំណាងវិទ្យាស្ថាន Lowy Institute

នាថ្ងៃចន្ទ ទី២៥ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា សៀ ឫទ្ធី បានបន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបពិភាក្សាការងារជាមួយតំណាងវិទ្យាស្ថាន Lowy Institute លោកស្រី Susannah Patton ប្រធានស្តីទីផ្នែកស្រាវជ្រាវក្នុងជំនួបទទួលទានអាហារថ្ងៃត្រង់។

ជាកិច្ចចាប់ផ្តើម លោកស្រី Susannah Patton បានជម្រាបជូនអំពីកិច្ចការងាររបស់វិទ្យាស្ថាន និងការស្រាវជ្រាវទាក់ទងនឹងគោលនយោបាយអន្តរជាតិនៅលើពិភពលោក និងកិច្ចការពាណិជ្ជកម្មនៅក្នុងតំបន់។ ជាក់ស្តែងនាពេលថ្មីៗនេះ វិទ្យាស្ថានបានសិក្សាអំពីលំហូរហិរញ្ញវត្ថុ និងជំនួយសម្រាប់ការអភិវឌ្ឍនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងយុទ្ធសាស្ត្រពាក់ព័ន្ធមួយចំនួននៅក្នុងតំបន់។

ក្នុងជំនួបពិភាក្សានេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានជម្រាបជូនអំពីបច្ចុប្បន្នភាពនៃបរិយាកាសវិនិយោគ និងសក្តានុពលរបស់កម្ពុជាសម្រាប់ការវិនិយោគនាពេលបច្ចុប្បន្ន ដោយបានសង្កត់ធ្ងន់លើគោលនយោបាយ និងទស្សនវិស័យប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ប្រមុខដឹកនាំកម្ពុជាដែលមាននិន្នាការលើកកម្ពស់ និងការពារសុខសន្តិភាពស្ថិរភាពនៅទូទាំងប្រទេសនិងក្នុងតំបន់។

សូមបញ្ជាក់ថា Lowy Institute គឺជាវិទ្យាស្ថានឯករាជ្យឈានមុខគេមួយនៅក្នុងប្រទេសអូស្ត្រាលីដែលទទួលបានការវាយតម្លៃខ្ពស់លើលទ្ធផលនៃការស្រាវជ្រាវរបស់វិទ្យាស្ថាន និងឥទ្ធិពលនៃការសិក្សាទាំងនេះទៅលើគោលនយោបាយទាំងក្នុងប្រទេសអូស្ត្រាលី និងនៅទូទាំងពិភពលោក។










## អ្នកឧកញ៉ា សៀ ឫទ្ធី ចូលរួមជាមួយគណៈប្រតិភូកម្ពុជា ក្នុងជំនួបពិភាក្សាការងារជាមួយដៃគូគ្រប់គ្រងក្រុមហ៊ុន Blackrock Investment Management (Global Infrastructure Partners)

នារសៀលថ្ងៃចន្ទ ទី២៥ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា សៀ ឫទ្ធី តំណាងសមាគមឧកញ៉ាកម្ពុជា បានចូលរួមជាមួយគណៈប្រតិភូកម្ពុជា ក្រោមការដឹកនាំដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបពិភាក្សាការងារជាមួយដៃគូគ្រប់គ្រងក្រុមហ៊ុន Blackrock Investment Management (Global Infrastructure Partners) ដឹកនាំដោយលោក Ari Droga ដោយមានការចូលរួមពីគណៈប្រតិភូអមដំណើររួមមានក្រសួង ស្ថាប័នកម្ពុជា និងផ្នែកឯកជនជាច្រើនរូប។

ក្នុងឱកាសនៃជំនួបនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់អំពីបច្ច័យវិជ្ជមាននានាជាហេតុនាំឱ្យកម្ពុជាគឺជាទីតាំងគួរពិចារណាជ្រើសទៅបណ្តាក់ទុនវិនិយោគ រួមមាន៖ សុខសន្តិភាព និងស្ថិរភាពនយោបាយ, លំនឹងម៉ាក្រូសេដ្ឋកិច្ច, កម្លាំងពលកម្មវ័យក្មេងដែលបើកទូលាយក្នុងការទទួលយកការបណ្តុះបណ្តាលថ្មីៗ, ការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលដល់ការរីកលូតលាស់នៃវិស័យឯកជន តាមរយៈវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន, ច្បាប់ស្តីពីវិនិយោគដែលមានភាពបត់បែន និងអនុគ្រោះខ្ពស់, ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងវិស័យភស្តុភារកម្មដែលបាននិងកំពុងអភិវឌ្ឍឱ្យកាន់តែមានភាពសម្បូរបែប និងប្រទាក់ក្រឡាជាមួយនឹងទីតាំងភូមិសាស្ត្រដែលមានអំណោយផលខ្ពស់។

ក្នុងឱកាសនោះក្រុមហ៊ុនក៏បានបង្ហាញឡើងអំពីបទពិសោធន៍របស់ខ្លួនក្នុងការបណ្តាក់ទុនវិនិយោគនៅក្នុងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅក្នុងប្រទេសអូស្ត្រាលី ដូចជាអាកាសយានដ្ឋាននៅទីក្រុងស៊ីដនី កំពង់ផែនៅទីក្រុងម៉ែលប៊ន និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសំខាន់ៗផ្សេងទៀតនៅលើពិភពលោករួមមានចក្រភពអង់គ្លេសជាដើម។

សូមបញ្ជាក់ផងដែរថា Blackrock Investment Management (Global Infrastructure Partners) គឺជាក្រុមហ៊ុនវិនិយោគពហុជាតិសាសន៍លំដាប់ពិភពលោកដែលមានទីស្នាក់ការកណ្តាលនៅទីក្រុងញូវយ៉កដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៨៨ហើយបាននិងកំពុងពង្រីក











## អ្នកឧកញ៉ា សៀ ឬទ្ធី ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបពិភាក្សាការងារជាមួយ លោក Paul Serra នាយកប្រតិបត្តិក្រុមហ៊ុន SunRice Group







នាថ្ងៃចន្ទ ទី២៥ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា សៀ ឬទ្ធី បានបន្តដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល បានទទួលជួបពិភាក្សាការងារជាមួយលោក Paul Serra នាយកប្រតិបត្តិក្រុមហ៊ុន SunRice Group ដោយ មានការចូលរួមពីគណៈប្រតិភូអមដំណើររួមមានក្រសួង ស្ថាប័នកម្ពុជា និងផ្នែកឯកជនជាច្រើនរូប។

តាមរយៈជំនួបនេះ លោកនាយកប្រតិបត្តិក្រុមហ៊ុន SunRice Group បានបង្ហាញពីចំណាប់អារម្មណ៍ក្នុងការធ្វើទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា ដើម្បីពិនិត្យលទ្ធភាពបណ្តាក់ទុនវិនិយោគបង្កើតរោងចក្រ និងនាំយកពូជព្រមទាំងបច្ចេកវិទ្យាបង្កបង្កើនផលស្រូវ Japonica មកប្រទេសកម្ពុជា។ ក្រុមហ៊ុន SunRice Group ក៏ត្រូវបានគេដឹងថាជាក្រុមហ៊ុនសញ្ជាតិអូស្ត្រាលីដំបូងគេដែលបាននាំចេញអង្ករពីកម្ពុជាទៅកាន់ទីផ្សារអូស្ត្រាលី និងនូវែលហ្សេឡង់ផងដែរ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានសម្តែងនូវក្តីសោមនស្សចំពោះការជួបពិភាក្សាការងារផ្លាស់ប្តូរយោបល់ ចែករំលែកបទពិសោធន៍ការងារទៅវិញទៅមកនាឱកាសនេះ។ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានជម្រាបជូនផងដែរអំពីបច្ចុប្បន្នភាពនៃបរិយាកាសវិនិយោគនៅកម្ពុជា ក៏ដូចជាសក្តានុពលនានាដែលកម្ពុជាមាន ស័ក្តិសមសម្រាប់ការជ្រើសរើសជាគោលដៅវិនិយោគក្នុងបរិការណ៍ពិភពលោកនាពេលបច្ចុប្បន្ន និងវឌ្ឍនភាពថ្មីៗនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងថាមពលនៅក្នុងប្រទេសកម្ពុជាដែលកាន់តែផ្តល់ភាពងាយស្រួលដល់ការធ្វើប្រតិបត្តិការពាណិជ្ជកម្ម ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ប្រមុខដឹកនាំកម្ពុជា។

ក្រុមហ៊ុន SunRice Group គឺជាក្រុមហ៊ុនកែច្នៃផលិតផលចំណីអាហារ និងអង្ករមួយក្នុងចំណោមក្រុមហ៊ុនធំៗនៅលើពិភពលោក ដែលមានដើមកំណើតនៅប្រទេសអូស្ត្រាលីតាំងពីឆ្នាំ១៩៥០ ហើយបច្ចុប្បន្នក្រុមហ៊ុនបានពង្រីកប្រតិបត្តិការរបស់ខ្លួនទៅកាន់ប្រទេសជាច្រើននៅជុំវិញពិភពលោក។

# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងជំនួបពិភាក្សាការងាររវាង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ជាមួយលោក Glenn Keys AO ស្ថាបនិក និងជាប្រធានក្រុមហ៊ុន Aspen Medical

នាព្រឹកថ្ងៃអង្គារ ទី២៦ ខែសីហា ឆ្នាំ២០២៥ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយលោក Glenn Keys AO ស្ថាបនិក និងជាប្រធានក្រុមហ៊ុន Aspen Medical ក្នុងជំនួបពិសាអាហារពេលព្រឹក ដោយមានការចូលរួមពី ឯកឧត្តមឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់, ឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា, ថ្នាក់ដឹកនាំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលដឹកនាំដោយអ្នកឧកញ៉ា សៀ ឬទ្ធី ផងដែរ។

ជាកិច្ចចាប់ផ្តើម លោកប្រធានក្រុមហ៊ុនបានថ្លែងអំណរគុណជូនដល់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីដែលបានអនុញ្ញាតឱ្យលោក និងសហការីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។ ក្នុងឱកាសនោះ លោកប្រធានក្រុមហ៊ុនបានលើកបង្ហាញអំពីប្រវត្តិការងារ និងបទពិសោធរបស់ក្រុមហ៊ុនដែលធ្លាប់បានអនុវត្តជោគជ័យនាពេលកន្លងមកលើគម្រោងសុខាភិបាលនៅក្នុងប្រទេសអូស្ត្រាលី ប្រទេសឥណ្ឌូនេស៊ី និងប្រទេសហ្វីជី។ បន្ថែមពីនោះ ក្រុមហ៊ុនក៏មានប្រតិបត្តិការសេវាសុខាភិបាលនៅក្នុងប្រទេសធំៗមួយចំនួនលើពិភពលោកដូចជាសហរដ្ឋអាម៉េរិក និង ចក្រភពអង់គ្លេសផងដែរ។ ក្រុមហ៊ុននឹងសិក្សាលម្អិតលើវិសាលភាពគ្របដណ្តប់សម្រាប់ការវិនិយោគនៅកម្ពុជា ហើយស្វែងរកកិច្ចសហការ ជាមួយអង្គភាពពាក់ព័ន្ធសំដៅបណ្តាក់ទុនវិនិយោគនាពេលអនាគត។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក្នុងឱកាសនោះក៏បានបង្ហាញការស្វាគមន៍ទៅកាន់ក្រុមហ៊ុនសម្រាប់គ្រោងការសិក្សាលម្អិតអំពីការវិនិយោគនៅកម្ពុជា។ បន្ថែមពីនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានលើកបង្ហាញអំពីសក្តានុពលចំពោះការវិនិយោគលើវិស័យសុខាភិបាលនៅក្នុង ប្រទេសកម្ពុជា និងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។










# ប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមជំនួបពិភាក្សាការងាររវាង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល និងលោកស្រី Navleen Prasad នាយកប្រតិបត្តិ ក្រុមប្រឹក្សាវិនិយោគអូស្ត្រាលី (Australia Investment Council) របស់រដ្ឋាភិបាលអូស្ត្រាលី







នាថ្ងៃអង្គារ ទី២៦ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា សៀ ឬទ្ធី បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងជំនួបពិភាក្សាការងារជាមួយលោកស្រី Navleen Prasad នាយកប្រតិបត្តិក្រុមប្រឹក្សាវិនិយោគអូស្ត្រាលី (Australia Investment Council) របស់រដ្ឋាភិបាលអូស្ត្រាលី។

នាឱកាសនេះ លោកស្រីនាយកប្រតិបត្តិបានសម្តែងគារវកិច្ចជូនចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងបានជម្រាបជូនអំពីប្រតិបត្តិការ ព្រមទាំងសកម្មភាពការងាររបស់ក្រុមប្រឹក្សាវិនិយោគអូស្ត្រាលី។ ស្ថាប័ននេះគឺជាតួអង្គសំខាន់មួយក្នុងការសម្របសម្រួល និងចាត់ចែងទុនវិនិយោគឯកជនអូស្ត្រាលី ដោយផ្តល់សេវាគាំទ្រដល់ក្រុមហ៊ុនវិនិយោគសំខាន់ៗរបស់អូស្ត្រាលីរាប់បញ្ចូលទាំងក្រុមហ៊ុនមូលធនសម្ព័ន្ធ (Venture Capital), Private Equity, Private Credit។ល។ ក្រុមប្រឹក្សាវិនិយោគអូស្ត្រាលីក៏បំពេញមុខងារជាស្ថាប័នជំរុញវិនិយោគ និងចាត់ចែងមូលនិធិប្រាក់សន្សំចូលនិវត្តន៍របស់ប្រទេសអូស្ត្រាលីដើម្បីប្រើប្រាស់ជាទុនសម្រាប់ទ្រទ្រង់ការវិនិយោគឯកជនផងដែរ។

ក្នុងកិច្ចពិភាក្សានេះ ក្រោយជម្រាបជូនក្រុមប្រឹក្សាវិនិយោគអូស្ត្រាលី បានជ្រាបអំពីសក្តានុពល និងបច្ច័យជាវិជ្ជមានសម្រាប់ការបណ្តាក់ទុនវិនិយោគនៅកម្ពុជា ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានអញ្ជើញលោកស្រីផ្ទាល់ និងក្រុមហ៊ុនអូស្ត្រាលីជាសមាជិកក្រុមប្រឹក្សាវិនិយោគអូស្ត្រាលី អញ្ជើញធ្វើទស្សនកិច្ចនៅកម្ពុជាដើម្បីពិនិត្យស្វែងរកឱកាសបណ្តាក់ទុកវិនិយោគផងដែរ។

ចូលរួមក្នុងកិច្ចប្រជុំពិភាក្សានេះដែរ លោក Stephen Higgins និងលោក Morgan Hart ដែលជាវិនិយោគិនអូស្ត្រាលីកំពុងបណ្តាក់ទុនវិនិយោគនៅកម្ពុជាផ្ទាល់ ក៏បានគូសបញ្ជាក់ពីការវិវត្តជាវិជ្ជមានរបស់កម្ពុជា ជូនលោកស្រីបានជ្រួតជ្រាបបន្ថែមផងដែរ។ ពិសេសជាងនេះ លោកក៏បានចែករំលែកនូវបទពិសោធរបស់ខ្លួនក្នុងការធ្វើប្រតិបត្តិការអាជីវកម្មនៅប្រទេសកម្ពុជា ដែលជំរុញឱ្យលោកស្រីមានចំណាប់អារម្មណ៍ជាខ្លាំងចំពោះកាលានុវត្តភាពដ៏សម្បូរបែបរបស់កម្ពុជាពិសេសតាមរយៈបទពិសោធរបស់វិនិយោគិនទាំងពីរក្រោយបានធ្វើទស្សនកិច្ចដោយផ្ទាល់ជាលើកដំបូងនៅកម្ពុជា។

# អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងដំណើរទស្សនកិច្ចស្វែងយល់ ពីការអភិវឌ្ឍនិងគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ (SYD)

កាលពីរសៀលថ្ងៃអង្គារ ទី២៦ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីបំពេញទស្សនកិច្ចស្វែងយល់ពីការអភិវឌ្ឍ និងគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិស៊ីដនី (SYD) ដែលជាគម្រោងវិនិយោគមួយរបស់ក្រុមហ៊ុន Global Infrastructure Partners (GIP)។

GIP គឺជាក្រុមហ៊ុនវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធឯករាជ្យឈានមុខគេមួយនៅលើពិភពលោក។ ក្រុមហ៊ុននេះមានឯកទេសក្នុងការវិនិយោគ កាន់កាប់ និងប្រតិបត្តិការទ្រព្យសកម្ម ហេដ្ឋារចនាសម្ព័ន្ធដ៏ធំ និងប្រទាក់ក្រឡានៅក្នុងវិស័យផ្សេងៗ។ បច្ចុប្បន្ន GIP ផ្តោតការវិនិយោគលើប្រភេទទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជា៖ (១) ថាមពល រួមមាន ថាមពលកកើតឡើងវិញ, ការផលិត និងចែកចាយថាមពល, ហេដ្ឋារចនាសម្ព័ន្ធឧស្ម័ន និងប្រេង (២) វិស័យដឹកជញ្ជូន រួមមាន អាកាសយានដ្ឋាន, កំពង់ផែ, ផ្លូវដែក, និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្សេងទៀត (៣) ហេដ្ឋារចនាសម្ព័ន្ធឌីជីថល រួមមាន មជ្ឈមណ្ឌលទិន្នន័យ, បណ្តាញខ្សែកាប Fiber Optic និងបង្គោលអង់តែនទូរសព្ទ, និង (៤) ការគ្រប់គ្រងកាកសំណល់ និងហេដ្ឋារចនាសម្ព័ន្ធទឹក។ ឯកឧត្តម ក៏បានផ្តល់ការណែនាំឱ្យក្រុមហ៊ុន GIP សម្លឹងមើលកាលានុវត្តភាពវិនិយោគនៅកម្ពុជា ជាពិសេសចូលរួមអនុវត្តគម្រោងក្រោមផែនការមេអភិវឌ្ឍន៍ឡូជីស្ទិក។

អាកាសយានដ្ឋានអន្តរជាតិស៊ីដនី គឺជាអាកាសយានដ្ឋានដែលមានភាពមមាញឹកមួយនៅក្នុងប្រទេសអូស្ត្រាលី និងជាច្រកអន្តរជាតិដ៏សំខាន់មួយដែលបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការតភ្ជាប់ទីក្រុងស៊ីដនីទៅកាន់ពិភពលោកទាំងមូល។ បច្ចុប្បន្នអាកាសយានដ្ឋាននេះត្រូវបានកាន់កាប់ដោយសម្ព័ន្ធវិនិយោគមួយឈ្មោះថា Sydney Aviation Alliance (SAA) និងដោយមានក្រុមហ៊ុន Sydney Airport Corporation Limited (SACL) ជាប្រតិបត្តិករក្នុងអាកាសយានដ្ឋាន។











# គណៈប្រតភូកម្ពុជាដឹកនាំដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ចាប់ផ្តើមបេសកកម្មទាក់ទាញ និងជំរុញវិនិយោគនៅទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី

ថ្ងៃពុធ ទី២៧ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មនៅទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី ដោយចាប់ផ្តើមពីដំណើរទស្សនកិច្ចស្វែងយល់នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍មែលប៊ន (Melbourne Convention and Exhibition Centre - MCEC) ព្រមទាំងជំនួបជាមួយតំណាងក្រុមហ៊ុន Plenary Group ដែលជាក្រុមហ៊ុនវិនិយោគហេដ្ឋារចនាសម្ព័ន្ធឯករាជ្យដ៏លេចធ្លោមួយនិងមានជំនាញក្នុងការអភិវឌ្ឍវិនិយោគ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាពិសេសគម្រោងនៅក្រោមទម្រង់ភាពជាដៃគូរវាងរដ្ឋ និងឯកជន (Public-Private Partnerships-PPP)។ ក្រុមហ៊ុននេះបានចូលរួមក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធជាច្រើនប្រភេទ រួមមាន៖ មន្ទីរពេទ្យ, សាលារៀន, តុលាការ, មជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍ (MCEC), ផ្លូវថ្នល់, ផ្លូវរថភ្លើង (Sydney Metro), ប្រព័ន្ធដឹកជញ្ជូនសាធារណៈ, និងការគ្រប់គ្រងទឹក និងកាកសំណល់ជាដើម។

ក្នុងឱកាសនៃទស្សនកិច្ចនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានលើកទឹកចិត្តឱ្យក្រុមហ៊ុនពិនិត្យលទ្ធភាពវិនិយោគលើការអភិវឌ្ឍមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍ស្រដៀងគ្នានេះនៅក្នុងប្រទេសកម្ពុជាផងដែរ។

គួរកត់សម្គាល់ថា មជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍ (MCEC) គឺជាកន្លែងសម្រាប់រៀបចំព្រឹត្តិការណ៍ដ៏ធំ និងល្បីល្បាញបំផុតមួយនៅប្រទេសអូស្ត្រាលី មានទីតាំងស្ថិតនៅកណ្តាលទីក្រុងមែលប៊ន ជាប់នឹងទន្លេ Yarra River ដែលផ្តល់លក្ខណៈងាយស្រួលក្នុងការធ្វើដំណើរ។ (MCEC) ត្រូវបានគ្រប់គ្រង និងដំណើរការដោយ Melbourne Convention and Exhibition Trust ដែលជាស្ថាប័នរដ្ឋមួយរបស់រដ្ឋបាលរដ្ឋវីក តូរៀ ហើយត្រូវបានគេចាត់ទុកថាជាមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍មួយដែលបំពាក់ដោយបច្ចេកវិទ្យាទំនើប និងមានលក្ខណៈស្និទ្ធស្នាល នឹងបរិស្ថានប្រកបដោយចីរភាពតាមរយៈការចាត់ចំណាត់ថ្នាក់ដោយ 6 Star Green Star Environmental Rating។










# អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងកិច្ចពិភាក្សាតុមូល និងទទួលទានអាហារថ្ងៃត្រង់ជាមួយតំណាងក្រុមហ៊ុន សមាគមធុរកិច្ច និងអ្នកជំនាញក្នុងវិស័យធុរកិច្ចនិងវិនិយោគនៅអូស្ត្រាលី











នាថ្ងៃពុធ ទី២៧ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងកិច្ចពិភាក្សាតុមូល និងទទួលទានអាហារថ្ងៃត្រង់ជាមួយតំណាងក្រុមហ៊ុន សមាគមធុរកិច្ច និងអ្នកជំនាញក្នុងវិស័យធុរកិច្ច និងវិនិយោគនៅអូស្ត្រាលី ដែលរៀបចំដោយ លោក Peter Horn អ្នកគ្រប់គ្រងទូទៅផ្នែកវិនិយោគ នៃគណៈកម្មការពាណិជ្ជកម្ម និងវិនិយោគអូស្ត្រាលី (The Australian Trade and Investment Commission-Austrade)។

ជាកិច្ចចាប់ផ្តើម លោក Peter Horn បានឡើងថ្លែងចំណាប់អារម្មណ៍អំពីទំនាក់ទំនងដ៏យូរអង្វែងរវាងកម្ពុជា-អូស្ត្រាលី និងសហប្រតិបត្តិការប្រកបដោយផ្លែផ្កាវាងប្រទេសទាំងពីរ ជាក់ស្តែងការចូលរួមរបស់ឧត្តមសេនីយ៍ឯក ចន សេនដឺសុន (Jonh Sanderson) ក្នុងតួនាទីនាពេលនោះជា មេបញ្ជាការរបស់កងកម្លាំងអន្តរជាតិនៃអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា (UNTAC) នៅក្នុងដំណើរការស្វែងរកសន្តិភាពនៅកម្ពុជា។

ក្នុងឱកាសនៃជំនួបនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានថ្លែងអំណរគុណទៅកាន់ភាគីអូស្ត្រាលីដែលបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាចូលរួមក្នុងដំណើរការស្វែងរកសន្តិភាពនៅកម្ពុជា។ ទន្ទឹមនឹងនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានបង្ហាញជូនអង្គពិធីអំពីបច្ចុប្បន្នភាពសក្តានុពលរបស់កម្ពុជាសម្រាប់ការវិនិយោគ ដោយបានសង្កត់ធ្ងន់លើទស្សនវិស័យ និងគោលនយោបាយប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

ជាមួយគ្នានេះ លោក Stephen Higgins និងលោក Morgan Hart វិនិយោគិនអូស្ត្រាលីកំពុងបណ្តាក់ទុនវិនិយោគនៅកម្ពុជាផ្ទាល់ក៏បានចូលរួមចែករំលែកបទពិសោធ និងផ្តល់សក្ខីភាពនៃការវិវត្តន៍ជាវិជ្ជមានរបស់កម្ពុជាបានដាក់ចេញនូវគោលនយោបាយអនុគ្រោះជាច្រើនសម្រួលការវិនិយោគនៅកម្ពុជា និងមានភាពល្អប្រសើរជាងបណ្តាប្រទេសផ្សេងទៀតនៅក្នុងតំបន់។

បន្ទាប់ពីបានស្តាប់ និងពិភាក្សាផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកវិនិយោគិនដែលជាសមាជិកអង្គពិភាក្សាក៏បានបង្ហាញចំណាប់អារម្មណ៍ក្នុងការធ្វើទស្សនកិច្ច និងស្វែងរកកាលានុវត្តភាពវិនិយោគនៅប្រទេសកម្ពុជាបន្ថែមផងដែរ។

# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាអមដំណើរឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ដើម្បីបំពេញទស្សនកិច្ចនៅមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍ របស់ក្រុមហ៊ុន Rio Tinto លើសកម្មភាពវិនិយោគក្នុងវិស័យរ៉ែ

នាថ្ងៃពុធ ទី២៧ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ក្នុងដំណើរទស្សនកិច្ចសិក្សាស្វែងយល់ពីសកម្មភាពវិនិយោគក្នុងវិស័យរ៉ែដែលប្រើប្រាស់បច្ចេកវិទ្យាទំនើបចុងក្រោយ និងនវានុវត្តន៍ថ្មីៗនៅមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍របស់ក្រុមហ៊ុន Rio Tinto (Rio Tinto Research and Development facility) នៅតំបន់ Bundoora ដោយមានការទទួលបដិសណ្ឋារកិច្ចពីលោក Stuart Watson ប្រធានផ្នែកយុទ្ធសាស្ត្របច្ចេកទេស។

នៅក្នុងដំណើរទស្សនកិច្ចនេះលោកប្រធានផ្នែកបានបង្ហាញអំពីរបកគំហើញថ្មីៗរបស់ក្រុមហ៊ុនដែលសុទ្ធសឹងជាមធ្យោបាយប្រកបដោយនវានុវត្តន៍និងមានសារៈសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពធ្វើប្រតិបត្តិការរុករក និងកែច្នៃរបស់ក្រុមហ៊ុន ក៏ដូចជាចូលរួមកាត់បន្ថយផលប៉ះពាល់ទៅលើបរិស្ថាន។ការប្រើប្រាស់គោលការណ៍ធុរកិច្ចដែលមានការទទួលខុសត្រូវខ្ពស់ក្នុងការវិនិយោគ បានឆ្លុះបញ្ចាំងយ៉ាងគត់មុតពីការយកចិត្តទុកដាក់ដល់សុខុមាលភាពសង្គមដ៏ប្រសើរ។

ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានអញ្ជើញលោកប្រធានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាដើម្បីស្វែងយល់អំពីវឌ្ឍនភាព និងកាលានុវត្តភាពវិនិយោគនៅក្នុងប្រទេសកម្ពុជា។










# អ្នកឧកញ៉ា ហេង ឡុង អនុប្រធាន និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធវរសេនីយ៍ឯក ព្រៀប ចំរើន នៅខេត្តត្បូងឃ្មុំ










នាថ្ងៃសៅរ៍ ទី៣០ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហេង ឡុង តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដោយអ្នកឧកញ៉ា ឧកញ៉ា ដែលជាសមាជិកក្រុមប្រឹក្សាភិបាល និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបបានចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពលោកវរសេនីយ៍ឯក ព្រៀប ចំរើន ជំនួយការសេនាធិការវរ២១៤ នៃកងពលតូចថ្មើរជើងលេខ២១ ដែលបាន ពលីជីវិតក្នុងបុព្វហេតុការពារបូរណភាពទឹកដីកាលពីថ្ងៃទី២៥ ខែ សីហា ឆ្នាំ២០២៥ ដោយពិធីបុណ្យត្រូវបានប្រារព្ធឡើងនៅទីបញ្ជាការវរសេនាតូចថ្មើរជើងលេខ២១៤ ស្ថិតក្នុងភូមិសំពៅផុសថ្មី ឃុំជីពាទ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

ជាមួយគ្នានេះ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ក៏ទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់ឯកឧត្តម ប៉ែន កុសល្យ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំផងដែរ។ ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា បានពាំនាំនូវសារចូលរួមរំលែកទុក្ខពី លោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខ និងថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជា ជូនក្រុមគ្រួសារ នៃសពផងដែរ។

មរណភាពរបស់លោកវរសេនីយ៍ឯក ព្រៀប ចំរើន គឺជាការបាត់បង់នូវស្វាមីដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា និងជាឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនៗហើយក៏ជាការបាត់បង់នូវយោធិនដ៏អង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពដ៏អង់អាចរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបាន។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធលោកវរសេនីយ៍ឯក ព្រៀប ចំរើន បានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

# អ្នកឧកញ៉ា ហេង ឡុង ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធសពលោកអនុសេនីយ៍ទោ ហេង តាំង នៅខេត្តកំពង់ចាម

នាថ្ងៃសៅរ៍ ទី៣០ ខែសីហា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហេង ឡុង តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដោយអ្នកឧកញ៉ា ឧកញ៉ា ជាសមាជិកក្រុមប្រឹក្សាភិបាល និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបបានបន្តចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពលោកអនុសេនីយ៍ទោ ហេង តាំង យោធិននៃកងពលអន្តរាគមន៍លេខ១ ដែលបានពលីជីវិតក្នុងបុព្វហេតុការពារបូរណភាពទឹកដីដោយពិធីបុណ្យត្រូវបានប្រារព្ធឡើងនៅវត្តកោះកែវ ស្ថិតក្នុងឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា ហេង ឡុង បាននាំនាំនូវសារចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធានក៏ដូចជាលិខិតរំលែកមរណទុក្ខ និងថវិកាមួយចំនួនពីសមាគមឧកញ៉ាកម្ពុជាជូនក្រុមគ្រួសារ នៃសពផងដែរ។

មរណភាពរបស់លោកអនុសេនីយ៍ទោ ហេង តាំង គឺជាការបាត់បង់នូវកុលបុត្រដ៏ឆ្នើម និងអង់អាចក្លាហានដោយបានធ្វើពលិកម្មនូវសាច់ស្រស់ឈាមស្រស់ប្រកបដោយភាពមោះមុតនៅក្នុងបុព្វហេតុការពារអធិបតេយ្យ និងបូរណភាពទឹកដី។ វីរភាពដ៏អង់អាចរបស់លោកនឹងស្ថិតក្នុងការចងចាំក្នុងដួងចិត្តប្រជាជនខ្មែរគ្រប់រូបគ្មានថ្ងៃបំភ្លេចបាន។

សូមឧទ្ទិសបបួងសួងដល់ដួងវិញ្ញាណក្ខន្ធលោកអនុសេនីយ៍ទោ ហេង តាំង បានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។










# ឧកញ៉ាបណ្ឌិត លី រិទ្ធ សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួម ពិធីបើកសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការសាលាអន្តរជាតិប្រូមស៍ហ្គ្រូវកម្ពុជា



ថ្ងៃសៅរ៍ ទី៦ ខែកញ្ញា ឆ្នាំ២០២៥ ឧកញ៉ាបណ្ឌិត លី រិទ្ធ សមាជិកក្រុមប្រឹក្សាភិបាល និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងពិធីបើកសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការសាលាអន្តរជាតិប្រូមស៍ហ្គ្រូវកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម Dominic Williams ឯកអគ្គរាជទូតនៃចក្រភពអង់គ្លេសប្រចាំព្រះរាជាណាចក្រកម្ពុជា។

ឧកញ៉ា កែវ សម្បត្តិ សមាជិកសមាគមឧកញ៉ាកម្ពុជា ជាស្ថាបនិក និងជាប្រធាននាយកប្រតិបត្តិ នៃសាលាអន្តរជាតិប្រូមស៍ហ្គ្រូវកម្ពុជា បានថ្លែងថា៖ «ការនាំយកម៉ាកយីហោសាលាដែលមានបទពិសោធអប់រំបណ្តុះបណ្តាលជិត ៥០០ឆ្នាំពីចក្រភពអង់គ្លេស មកកាន់កម្ពុជាគឺមិនត្រឹមតែជាការនាំយកសាលារៀនដែលមានគុណភាពខ្ពស់ប៉ុណ្ណោះទេតែថែមទាំងនាំមកនូវទំនុកចិត្តចំពោះការអប់រំមកជូនដល់មាតាបិតាអាណាព្យាបាលសិស្សនៅកម្ពុជាយើងផងដែរដើម្បីជួយសម្រេចនូវរាល់ការរំពឹងទុក និងក្តីសង្ឃឹមរបស់ពួកគាត់ដែលមានចំពោះបុត្រធីតារបស់ខ្លួនហើយនេះក៏ជាការចូលរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលក្នុងការលើកស្ទួយវិស័យអប់រំនៅកម្ពុជាផងដែរ។» សូមបញ្ជាក់ថា អន្តរជាតិប្រូមស៍ហ្គ្រូវកម្ពុជា គឺជាសាលាមួយកំពុងឈានមុខគេក្នុងការផ្តល់នូវគុណភាពខ្ពស់នៃការអប់រំនៅចក្រភពអង់គ្លេស ។











# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគទៅកាន់សាធារណរដ្ឋប្រជាមានិតចិន

















យោងតាមសំណើពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំងអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និង អ្នកឧកញ៉ា គួន ធីតា ប្រធានអនុគណៈកម្មការទំនាក់ទំនង និងធុរកិច្ចដើម្បីដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលមានសមាសភាពសរុបចំនួន ១៧រូបរួមមាន៖ អ្នកឧកញ៉ា ទី គឹមស្រ៊ាន, អ្នកឧកញ៉ា ឌុក ទីប៉ាណា, ឧកញ៉ា កង លាប, អ្នកឧកញ៉ា សំ សុខនឿន, ឧកញ៉ាបណ្ឌិត លី រិទ្ធ, អ្នកឧកញ៉ា អ៊ឹង លីហេង, ឧកញ៉ា ម៉ៅ បញ្ញពណ៌, ឧកញ៉ា សូ សុខប៊ុនលីម, ឧកញ៉ា កែវ បូណ៌ភិរក្ស, ឧកញ៉ា តាំង ធា, ឧកញ៉ា ចេង ខេង, អ្នកឧកញ៉ា លី សុភាព ព្រមទាំងមន្ត្រី នៃលេខាធិការដ្ឋានមួយចំនួនទៀត ចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៥។

សូមបញ្ជាក់ថា អ្នកឧកញ៉ា គួន ធីតា នឹងដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ក្នុងឱកាសបំពេញការងារនៅទីក្រុងសៀមិន នាថ្ងៃទី៧-៩ ខែកញ្ញា ឆ្នាំ២០២៥ ដោយ អ្នកឧកញ៉ា ហ៊ុន ឡាក់ នឹងដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាក្នុងពេលបំពេញបេសកកម្មនៅទីក្រុងហុងកុងចាប់ពីថ្ងៃទី៩-១២ ខែកញ្ញា ឆ្នាំ២០២៥។

បេសកកម្មនេះបានចាប់ផ្តើមនៅទីក្រុងសៀមិន ដោយនាល្ងាចថ្ងៃអាទិត្យ ទី៧ ខែកញ្ញា ឆ្នាំ២០២៥ អ្នកឧកញ៉ា គួន ធីតា ប្រធានអនុគណៈកម្មការទំនាក់ទំនង និងធុរកិច្ច បានដឹកនាំគណៈ ប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឱកាស ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម ចាវ ឡុង (Zhao Long) អភិបាលខេត្តហ្វ៊ូជៀន នៃសាធារណរដ្ឋប្រជាមានិតចិន។

ក្រោយជំនួបសម្តែងការគួរសម និងពិភាក្សាការងារនេះរដ្ឋបាលខេត្តហ្វូជៀនក៏បានរៀបចំពិធីលៀងសាយភោជន៍ទទួលស្វាគមន៍គណៈប្រតិភូកម្ពុជានិងប្រទេសផ្សេងៗទៀតដែលអញ្ជើញចូលរួមក្នុងពិព័រណ៍អន្តរជាតិចិនលើកទី២៥ សម្រាប់ការវិនិយោគ និងពាណិជ្ជកម្ម (CIFIT) នេះផងដែរ។

# សមាគមឧកញ៉ាកម្ពុជា រៀបចំជំនួបផ្គូផ្គងធុរកិច្ចនិងពិសារភោជនាហារ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសមាគមវិនិយោគិនចិនមីននៅកម្ពុជា

ថ្ងៃអាទិត្យ ទី៧ ខែកញ្ញា ឆ្នាំ២០២៥ អ្នកឧកញ៉ា គួន ធីតា សមាជិកក្រុមប្រឹក្សាភិបាល និងជាប្រធានអនុគណៈកម្មការទំនាក់ទំនង និងធុរកិច្ច និងអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិកាព្រមទាំងសមាជិកប្រតិភូសមាគមឧកញ៉ាកម្ពុជាបានចូលរួមពិធីពិសាអាហារធុរកិច្ចរវាងសមាគមអ្នកវិនិយោគជនជាតិមីនចិននៅកម្ពុជា និងសមាគមឧកញ៉ាកម្ពុជាដែលប្រារព្ធធ្វើឡើងនៅសណ្ឋាគារ Xiamen Nikko Hotel ខេត្ត ហ្វូជៀន ទីក្រុងសៀមិន ប្រទេសចិន។

ពិធីស្វាគមន៍ និងពិសាអាហារធុរកិច្ចនេះ គឺការទទួលបដិសណ្ឋារកិច្ច និងផ្តល់កិត្តិយសដោយលោក Lin Xiangrong ប្រធានសមាគមអ្នកវិនិយោគជនជាតិមីនចិននៅកម្ពុជា ដោយមានការចូលរួមពីប្រតិភូធុរជនចិនជាច្រើនរូប ដើម្បីជាកិច្ចស្វាគមន៍ និងផ្តល់ជាឱកាសដល់ប្រតិភូធុរជននៃសមាគមទាំងពីរបង្កើតទំនាក់ទំនងល្អ ស្វែងយល់ និងផ្គូផ្គងធុរកិច្ចទៅវិញទៅមក។

ជាកិច្ចចាប់ផ្តើមលោក Lin Xiangrong បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះប្រតិភូកម្ពុជា ដែលធ្វើដំណើរមកកាន់ទីក្រុងសៀមិន នាក្នុងឱកាសបំពេញបេសកកម្មចូលរួម “សន្និសីទស្តីពីកិច្ចសហប្រតិបត្តិការវិនិយោគចិន-កម្ពុជា” និង “ពិព័រណ៍អន្តរជាតិចិន លើកទី២៥” ។

ក្នុងឱកាសពិធីនេះ អ្នកឧកញ៉ាបានឡើងថ្លែងចំណាប់អារម្មណ៍ចែករំលែកជូនភាគីចិនអំពីសារតារ បេសកកម្ម និងតួនាទីស្នូលរបស់សមាគម ដោយបានរំលេចជូនប្រតិភូធុរជនចិនថា សមាគមឧកញ៉ាកម្ពុជា ជាបណ្តុំធុរជន និងវិនិយោគិនមកពីចម្រុះវិស័យ ដែលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា។ លើសពីនេះ អ្នកឧកញ៉ាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក Lin Xiangrong ប្រធានសមាគមអ្នកវិនិយោគជនជាតិមីនចិននៅកម្ពុជា និងលោក Yang Dafa ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសហ្វូជៀននៅកម្ពុជាសម្រាប់ការស្វាគមន៍យ៉ាងកក់ក្តៅ ដែលផ្តល់នូវជំនួបដ៏មានអត្ថប្រយោជន៍ និងជាអនុស្សាវរីយ៍ជាទីចងចាំរវាងសមាគមទាំងពីរសម្រាប់កិច្ចសហប្រតិបត្តិការជាមួយគ្នានាពេលអនាគត។













# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធី បើកពិព័រណ៍អន្តរជាតចិនលើកទី២៥ សម្រាប់ការវិនិយោគ និងពាណិជ្ជកម្ម (CIFIT) នៅទីក្រុងសៀមិន ខេត្តហ្វ៊ូជៀន សាធារណរដ្ឋប្រជាមានិតចិន














ថ្ងៃចន្ទ ទី៨ខែកញ្ញា ឆ្នាំ២០២៥ អ្នកឧកញ៉ា គួន ធីតា សមាជិកក្រុមប្រឹក្សាភិបាល និងជាប្រធានអនុគណៈកម្មការទំនាក់ទំនងនិងធុរកិច្ច និងអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ព្រមទាំងសមាជិកប្រតិភូសមាគមឧកញ៉ាកម្ពុជា បានចូលរួមក្នុងពិធីបើក "ពិព័រណ៍អន្តរជាតិចិនលើកទី២៥ សម្រាប់ការវិនិយោគ និងពាណិជ្ជកម្ម" (The 25th China International Fair for Investment and Trade - CIFIT) ដែលរៀបចំឡើងនៅទីក្រុងសៀមិន ខេត្តហ្វ៊ូជៀន សាធារណរដ្ឋប្រជាមានិតចិន។

សូមបញ្ជាក់ថា ពិធីបើកពិព័រណ៍នាឱកាសនេះរៀបចំឡើងក្រោមអធិបតីភាពឯកឧត្តម ហឺ លីហ្វឹង (He Lifeng) ឧបនាយករដ្ឋមន្ត្រី និងជាសមាជិកការិយាល័យនយោបាយ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន ព្រមទាំងមានការចូលរួមយ៉ាងកុះករពីថ្នាក់ដឹកនាំធំៗរបស់សាធារណរដ្ឋប្រជាមានិតចិន ទីភ្នាក់ងារជំរុញការវិនិយោគបរទេស អង្គការអន្តរជាតិ សហគ្រាស និងតំណាងធុរកិច្ច មកពីប្រមាណ ៣០ប្រទេសជុំវិញពិភពលោក។





















ជាមួយគ្នានេះ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏បានអញ្ជើញថ្លែងសុន្ទរកថាគន្លឹះក្នុងពិធីបើកជាផ្លូវការនេះផងដែរ ដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានចូលរួមអបអរសាទរ និងថ្លែងអំណរគុណចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍ដ៏សំខាន់នេះឡើងសម្រាប់លើកកម្ពស់កិច្ចសហប្រតិបត្តិការវិនិយោគ និងពាណិជ្ជកម្មព្រមទាំងជំរុញចក្ខុវិស័យនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ ព្រមទាំងបានជម្រាបជូនអង្គពិធីអំពីសមិទ្ធផលថ្មីៗក៏ដូចជាវឌ្ឍនភាពនៃកិច្ចការងារវិនិយោគរបស់កម្ពុជាដែលសម្រេចបានកាលពីឆ្នាំ២០២៤ អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺចំនួន៤១៤គម្រោងដែលមានទុនប្រមាណ ៦,៩ពាន់លានដុល្លារ កើនឡើង៤០% បើធៀបនឹងឆ្នាំ២០២៣។ ក្នុងរយៈពេល ៨ខែដំបូងនៃឆ្នាំ២០២៥ កម្ពុជាបានអនុម័តគម្រោងវិនិយោគចំនួន ៤៩១គម្រោង មានទុន ៧,២ពាន់លានដុល្លារ ដោយរំពឹងថាចំនួនគម្រោងវិនិយោគនៅឆ្នាំ២០២៥នេះនឹងកើនឡើងជាបន្តបន្ទាប់បន្ថែមទៀតដែលអាចបង្កើតការងារបានជាង ៤០ម៉ឺនកន្លែងជូនប្រជាពលរដ្ឋ។ ការនាំចេញរបស់កម្ពុជាទៅក្នុងទីផ្សារតំបន់ និងពិភពលោកក៏បន្តកើនឡើង ពោលនៅឆ្នាំ២០២៤ ការនាំចេញពីកម្ពុជាឈានដល់ ២៦,៦ពាន់លានដុល្លារ កើនឡើង១៣,៦% បើធៀបនឹងឆ្នាំ២០២៣។ តួលេខទាំងនេះបានបង្ហាញអំពីភាពធន់ ភាពបើកចំហ និងបរិយាកាសស្វាគមន៍របស់កម្ពុជាទៅកាន់វិនិយោគិន។

ទន្ទឹមនឹងនេះ ក្រោមក្របខណ្ឌនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវភាពជាដៃគូរវាងកម្ពុជា និងចិនបាននាំមកនូវមិនត្រឹមតែការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះទេ ថែមទាំងមានការអភិវឌ្ឍជំនាញ ការផ្ទេរបច្ចេកវិទ្យា និងការធ្វើឱ្យប្រសើរឡើងនូវឧស្សាហកម្មផងដែរ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានជម្រាបជូនអំពីវឌ្ឍនភាពគម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗទាំងផ្លូវគោក កំពង់ផែ អាកាសយានដ្ឋាន និងប្រព័ន្ធឌីជីថលជាដើមដែលចិនគឺជាដៃគូដ៏សំខាន់បានចូលរួមវិនិយោគលើគម្រោងជាច្រើនដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រីជឿជាក់ថាពិព័រណ៍អន្តរជាតិ CIFIT នឹងផ្តល់ឱកាសកាន់តែច្រើនសម្រាប់កិច្ចសហការរួមគ្នាទាំងការវិនិយោគ និងពាណិជ្ជកម្ម។

# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមសន្និសីទ Future Investment Conference 2025 Opening & Plenary Session និងទស្សនកិច្ចមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិក្រុងសៀមិន

កាលពីរសៀលថ្ងៃចន្ទ ទី៨ ខែកញ្ញា ឆ្នាំ២០២៥ អ្នកឧកញ៉ា គួន ធីតា សមាជិកក្រុមប្រឹក្សាភិបាល និងជាប្រធានអនុគណៈកម្មការទំនាក់ទំនងនិងធុរកិច្ច និងអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ព្រមទាំងសមាជិកប្រតិភូសមាគមឧកញ៉ាកម្ពុជា បានចូលរួមសន្និសីទ Future Investment Conference 2025 Opening & Plenary Session ព្រមទាំងបានចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឱកាសបំពេញទស្សនកិច្ចមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិក្រុងសៀមិន (Xiamen International Convention and Exhibition Center) ក្រោយបានចូលរួមពិធីបើកពិព័រណ៍អន្តរជាតិចិនលើកទី២៥ សម្រាប់ការវិនិយោគ និងពាណិជ្ជកម្ម (The 25th China International Fair for Investment and Trade - CIFIT) ក្នុងទីក្រុងសៀមិន ខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិនផងដែរ។

















# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមវេទិកាខ្សែក្រវាត់ និងផ្លូវ សម្រាប់ការផ្លាស់ប្តូរកិច្ចសហប្រតិបត្តិការវិនិយោគអន្តរជាតិ


















នាព្រឹកថ្ងៃអង្គារ ទី៩ ខែកញ្ញា ឆ្នាំ២០២៥ អ្នកឧកញ៉ា គួន ធីតា សមាជិកក្រុមប្រឹក្សាភិបាល និងជាប្រធានអនុគណៈកម្មការទំនាក់ទំនង និងធុរកិច្ច និងអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ព្រមទាំងសមាជិកប្រតិភូសមាគមឧកញ៉ាកម្ពុជា បានចូលរួមវេទិកាខ្សែក្រវ៉ាត់ និងផ្លូវ សម្រាប់ការផ្លាស់ប្តូរកិច្ចសហប្រតិបត្តិការវិនិយោគអន្តរជាតិ (Thematic Session on Belt and Road International investment cooperation Exchange) ដែលជាវេទិកាដ៏សំខាន់សម្រាប់ការតភ្ជាប់ វិនិយោគ ពាណិជ្ជកម្ម និងវិបុលភាពរួមគ្នា។

ក្នុងឱកាសនេះដែរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏បានអញ្ជើញថ្លែងសុន្ទរកថាគន្លឹះក្នុងវេទិកាដ៏មានសារៈសំខាន់នេះ ដោយឯកឧត្តមបានបញ្ជាក់ថា សម្រាប់ប្រទេសកម្ពុជា គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ ពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ពិសេសគឺការចូលរួមកសាងមូលដ្ឋានគ្រឹះសម្រាប់កំណើនហេដ្ឋារចនាសម្ព័ន្ធទាំងផ្លូវគោក ស្ពាន អាកាសយានដ្ឋាន រួមទាំងផ្លូវទឹកផងដែរ។

ឯកឧត្តមបានបន្ថែមថា បទពិសោធន៍របស់កម្ពុជាគឺជាភស្តុតាងដែលសម្រេចបានពីគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ តាមរយៈភាពជាដៃគូដើម្បីផ្លាស់ប្តូរហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងសេដ្ឋកិច្ចកាន់តែប្រសើរឡើង។ ជាមួយនឹងកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅ ចក្ខុវិស័យនេះនឹងបន្តជំរុញការអភិវឌ្ឍមិនត្រឹមតែប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់តំបន់ និងពិភពលោកផងដែរ។ កម្ពុជានឹងបន្តជំរុញឱ្យកិច្ចសហប្រតិបត្តិការនេះមាននិរន្តរភាព តម្លាភាព និងទទួលបានផលប្រយោជន៍ទៅវិញទៅមក មិនត្រឹមតែនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅវិស័យផ្សេងទៀតមានជាអាទិ៍ការអភិវឌ្ឍបៃតង ការផ្លាស់ប្តូរបច្ចេកវិទ្យាឌីជីថល និងធនធានមនុស្សជាដើម។

# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចាប់ផ្តើមបេសកកម្ម នៅទីក្រុងហុងកុង តាមរយៈការចូលរួមកិច្ចប្រជុំកំពូលខ្សែក្រវាត់ និងផ្លូវ លើកទី១០ (The 10th Belt and Road Summit)

នាព្រឹកថ្ងៃពុធ ទី១០ ខែកញ្ញា ឆ្នាំ២០២៥នេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងកិច្ចប្រជុំកំពូលខ្សែក្រវាត់ និងផ្លូវ លើកទី១០ (The 10th Belt and Road Summit) ដែលប្រព្រឹត្តទៅក្នុងទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៥ ក្រោមប្រធានបទកិច្ចសហប្រតិបត្តិការសម្រាប់ការផ្លាស់ប្តូរ – បង្កើតអនាគតរួមគ្នា (Collaboration for change -Shape a shared Future )។

ក្នុងឱកាសនេះ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏បានអញ្ជើញថ្លែងសុន្ទរកថាគន្លឹះក្នុងកិច្ចប្រជុំកំពូលនេះផងដែរ។

សូមបញ្ជាក់ថា កិច្ចប្រជុំកំពូលខ្សែក្រវាត់ និងផ្លូវ លើកទី១០ បានប្រមូលផ្តុំទៅដោយមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាល ថ្នាក់ដឹកនាំធុរកិច្ច វាគ្មិនអន្តរជាតិ និងអ្នកចូលរួមប្រមាណ ៦០០០នាក់មកពី៧០ប្រទេសទូទាំងពិភពលោក។ យ៉ាងហោចណាស់មានគម្រោងវិនិយោគប្រមាណ ២៩០ គម្រោង និងការផ្គូផ្គងធុរកិច្ចច្រើនជាង៨០០ ត្រូវបានបង្ហាញ និងរៀបចំឡើងតាមរយៈកិច្ចប្រជុំនេះ។ កិច្ចប្រជុំកំពូលខ្សែក្រវាត់ និងផ្លូវ គឺជាវេទិកាអន្តរជាតិដ៏សំខាន់មួយសម្រាប់លើកកម្ពស់កិច្ចសហប្រតិបត្តិការពហុភាគី និងឱកាសអាជីវកម្ម។













# សន្និសីទស្តីពីកិច្ចសហប្រតិបត្តិការវិនិយោគចិន-កម្ពុជា រៀបចំដោយ សមាគមឧកញ៉ាកម្ពុជា និងសមាគមអ្នកវិនិយោគចិនជនជាតិមីន នៅកម្ពុជាទទួលបានជោគជ័យដ៏ត្រចះត្រចង់




















នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៥ សមាគមឧកញ៉ាកម្ពុជា និងសមាគមអ្នកវិនិយោគចិនជនជាតិមីននៅកម្ពុជា បានសហការរៀបចំ «សន្និសីទស្តីពីកិច្ចសហប្រតិបត្តិការវិនិយោគចិន-កម្ពុជា» ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងឯកឧត្តម Wiao Kui អភិបាលរងខេត្តហ្វ៊ូជៀន សាធារណរដ្ឋប្រជាមានិតចិន ដោយមានការចូល រួមពីប្រតិភូសមាគមឧកញ៉ាកម្ពុជា ដឹកនាំដោយអ្នកឧកញ៉ា គួន ធីតា សមាជិកក្រុមប្រឹក្សាភិបាល និងជាប្រធានអនុគណៈកម្មការទំនាក់ទំនង និងធុរកិច្ច ព្រមទាំងការចូលរួមពីធុរជនចិនមកពីចម្រុះវិស័យជាច្រើននាក់។

សន្និសីទនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយបរិយាកាសធុរកិច្ច និងទាក់ទាញការវិនិយោគរវាងប្រទេសទាំងពីរដើម្បីលើកកម្ពស់ទំនាក់ទំនង និងសកម្មភាពពាណិជ្ជកម្មចិន-កម្ពុជា ឱ្យកាន់តែឈានខ្ពស់មួយកម្រិតថែមទៀត។

ឯកឧត្តម Wiao Kui អភិបាលរងខេត្តហ្វ៊ូជៀនបានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដែលបានដឹកនាំប្រតិភូកម្ពុជាមកបំពេញទស្សនកិច្ចជំរុញនិងទាក់ទាញវិនិយោគនៅទីក្រុងសៀមិន។ ឯកឧត្តមអភិបាលរងបានមានប្រសាសន៍ថាសន្និសីទនាថ្ងៃ នេះ គឺជាវេទិកាដ៏មានសារៈសំខាន់មួយដែលផ្តល់ឱកាសដល់ធុរជនបានកសាងទំនាក់ទំនងជាមួយគ្នា និងបានលើកទឹកចិត្តដល់ធុរជន និងវិនិយោគិននៃប្រទេសទាំងពីរទាញយកឱកាសនេះក្នុងការផ្គូផ្គងធុរកិច្ចទៅវិញទៅមកសម្រាប់កិច្ចសហការធុរកិច្ចនាពេលខាងមុខ។
















ថ្លែងក្នុងឱកាសនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ចែករំលែកអំពីអំពីកត្តាទាក់ទាញវិនិយោគិនបរទេសឱ្យមកបោះទុនវិនិយោគនៅកម្ពុជា ដែលរួមមាន (១) សន្តិភាព និងស្ថិរភាពនយោបាយ (២) ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច (៣) ច្បាប់ស្តីពីវិនិយោគដែលមានការលើកទឹកចិត្ត និងបើកចំហទូលំទូលាយ (៤) រាជរដ្ឋាភិបាលមានការគាំទ្រ និងជួយសម្របសម្រួលដល់វិស័យឯកជន (៥) ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ មានការអភិវឌ្ឍ និងការតភ្ជាប់កាន់តែល្អប្រសើរ (៦) ប្រជាជនវ័យក្មេងប្រកបដោយថាមពល (៧) ទីតាំងភូមិសាស្ត្រអំណោយផលស្ថិតនៅចំកណ្តាលនៃមហាអនុតំបន់ទន្លេមេគង្គ មានប្រជាជនចំនួន ២៥០លាននាក់, តំបន់អាស៊ាន មានប្រជាជន ៦៧១លាននាក់, និងក្នុងក្របខណ្ឌ RCEP មានប្រជាជន ២.៣ពាន់លាននាក់ព្រមទាំងកត្តាបន្ទាប់បន្សំផ្សេងៗទៀត។

ជាកិច្ចបន្ទាប់ អ្នកឧកញ៉ា គួន ធីតា បានឡើងថ្លែងចំណាប់អារម្មណ៍ចែករំលែកជូនភាគីចិនអំពីសាវតារ បេសកកម្ម និងតួនាទីស្នូលរបស់សមាគម ដោយបានរំលេចជូនប្រតិភូធុរជនចិនថា សមាគមឧកញ៉ាកម្ពុជា ជាបណ្តុំធុរជន និងវិនិយោគិនមកពីចម្រុះវិស័យ ដែលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា។ សូមជម្រាបផងដែរថា ក្នុងឱកាសនៃសន្និសីទនេះ សមាគមទាំងពីរបានព្រមព្រៀងចុះអនុស្សរណៈយោគយល់គ្នាក្នុងគោលបំណងពង្រឹងការវិនិយោគទ្វេភាគី សម្របសម្រួលការផ្លាស់ប្តូរសកម្មភាពសេដ្ឋកិច្ចនិងពាណិជ្ជកម្ម និលើកកម្ពស់កាលានុវត្តភាព និងបរិយាកាសធុរកិច្ចរវាងកម្ពុជា ចិន ដោយផ្តោតលើកិច្ចសហប្រត្តិការលើ៣ចំណុចសំខាន់ៗ ១)ការលើកកម្ពស់ធុរកិច្ច និងវិនិយោគ ២)ការផ្លាស់ប្តូរពាណិជ្ជកម្ម និងការផ្គូផ្គងធុរកិច្ច និង ៣)ការផ្លាស់ប្តូរចំណេះដឹង និងការកសាង

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ដឹកនាំគណៈប្រតិភូកម្ពុជា មានសមាសភាពចូលរួមពីសមាគមឧកញ៉ាកម្ពុជា ជួបផ្គូផ្គងធុរកិច្ចជាមួយសមាជិក សភាពាណិជ្ជកម្មចិនប្រចាំក្រុងហុងកុង

នាថ្ងៃពុធ ទី១០ ខែកញ្ញា ឆ្នាំ២០២៥ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុ ប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជាមានសមាសភាពចូលរួមពីសមាគមឧកញ៉ាកម្ពុជា ជួបផ្គូផ្គងធុរកិច្ចជាមួយសមាជិកសភាពាណិជ្ជកម្មចិនប្រចាំក្រុងហុងកុង ដឹកនាំដោយលោកបណ្ឌិត Jonathan Choi ប្រធានសភាពាណិជ្ជកម្មប្រចាំក្រុងហុងកុង ព្រមទាំងជាប្រធានក្រុមហ៊ុន Sunwah Group និងសហភាពសហគ្រិនតំបន់ឈូងសមុទ្រពិសេស ក្វាងទុង ហុងកុង ម៉ាកាវ ( Guangdong-HK- Macao Bay Area Entrepreneurs Alliance)។

កម្មវិធីនាឱកាសនេះរៀបចំឡើងក្នុងគោលបំណងដើម្បីផ្គូផ្គងវិនិយោគិនពីប្រទេសកម្ពុជាមានសមាសភាពពីសមាគមឧកញ៉ាកម្ពុជា និងវិនិយោគិនចិនជាសមាជិកសភាពាណិជ្ជកម្មចិនប្រចាំក្រុងហុងកុង បានជួបពិភាក្សាផ្លាស់ប្តូរយោបល់ និងស្វែងរកឱកាសវិនិយោគនៅកម្ពុជា។

តាមរយៈកម្មវិធីនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានស្នើសុំឱ្យវិនិយោគិនទាំងអស់បន្តស្វែងរកឱកាសវិនិយោគនៅកម្ពុជាលើគ្រប់វិស័យ ដោយហេតុថាកម្ពុជាមានសក្តានុពលវិនិយោគប្រកួតប្រជែងជាមួយប្រទេសផ្សេងទៀតនៅក្នុងតំបន់រាប់ចាប់ពីស្ថិរភាពនយោបាយ, ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, មានទីផ្សារសេរី, មានកម្លាំងពលកម្មវ័យក្មេងដែលអាចបណ្តុះបណ្តាលបាន, ពិសេសរាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** គាំទ្រយ៉ាងពេញទំហឹងចំពោះធុរកិច្ច។














# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងជំនួបពិភាក្សាការងារជាមួយ លោកសាស្ត្រាចារ្យ Frederick Ma ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង











នារសៀលថ្ងៃពុធ ទី១០ ខែកញ្ញា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងជំនួបពិភាក្សាការងារជាមួយលោកសាស្ត្រាចារ្យ Frederick Ma ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង។ក្នុងជំនួបនាឱកាសនេះ ភាគីទាំងពីរបានផ្លាស់ប្តូរយោបល់លើលទ្ធផលការងារដែលសម្រេចបានក្រោយការចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤កន្លងទៅ។

លោកសាស្ត្រាចារ្យថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រីដែលបានអញ្ជើញដឹកនាំគណៈប្រតិភូនិង វិនិយោគិនកម្ពុជាចូលរួមព្រមទាំងបានផ្តល់សុន្ទរកថាគន្លឹះក្នុងកិច្ចប្រជុំកំពូលខ្សែក្រវាត់ និងផ្លូវ លើកទី១០ ក្នុងក្រុងហុងកុង។ លោកសាស្ត្រាចារ្យបានជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីផងដែរអំពីសក្តានុពលរបស់ក្រុងហុងកុងព្រមទាំងបានបញ្ជាក់អំពីការបើកការិយាល័យរបស់ក្រុម ប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុងនៅកម្ពុជា កាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ក្រោយបានចុះអនុស្សរណៈនៃការយោគយល់គ្នារួចរាល់។ រាប់ បញ្ចូលទាំងកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុងមានការិយាល័យសរុបចំនួន ៥១នៅទូទាំងពិភពលោក។ លោកសាស្ត្រាចារ្យបាន បន្ថែមថា កិច្ចសហប្រតិបត្តិការជាមួយប្រទេសនានានៅក្នុងតំបន់អាស៊ានបានកើនឡើងគួរឱ្យកត់សម្គាល់ហើយលោកសាស្ត្រាចារ្យមានជំហរ រឹងមាំនឹងបន្តពង្រីកកិច្ចសហប្រតិបត្តិការនេះឱ្យបានកាន់តែទូលំទូលាយ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណចំពោះការអញ្ជើញឯកឧត្តមចូលរួម និងថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំកំពូលខ្សែក្រវាត់ និងផ្លូវលើកទី១០។ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល បានមានបំណងរៀបចំកម្មវិធីផ្គូផ្គងធុរកិច្ចកម្ពុជាចិននៅប្រទេសកម្ពុជាដែលក្នុងនោះ ស្នើសុំឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុងពិនិត្យលទ្ធភាពដឹកនាំគណៈប្រតិភូចូលរួម ដើម្បីជំរុញកិច្ចការងារវិនិយោគរវាងប្រទេសទាំងពីរ។ កម្ពុជាជាប្រទេសមានសេដ្ឋកិច្ចបើកចំហ និងអនុញ្ញាតឱ្យវិនិយោគិនបណ្តាក់ទុនលើគ្រប់វិស័យ។ តាមរយៈកិច្ចប្រជុំនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានស្នើសុំបទពិសោធន៍របស់លោកសាស្ត្រាចារ្យក្នុងការរៀបចំ និងគ្រប់គ្រងប្រព័ន្ធស្ថានីយរថភ្លើងក្រោមដី (MRT) ផងដែរ ដោយហេតុថា លោកសាស្ត្រាចារ្យមានបទពិសោធន៍ច្រើនឆ្នាំលើការគ្រប់គ្រងប្រភេទរថភ្លើងក្រោមដីក្នុងប្រទេសចិនមានជាអាទិ៍នៅទីក្រុងប៉េកាំង ទីក្រុងសិនជិន ទីក្រុងហាងចូវ និងប្រទេសអូស្ត្រាលីជាដើម។

# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលពេញអង្គ លើកទី១០ អាណត្តិទី១ ត្រីមាសទី៣ ឆ្នាំ២០២៥



នារសៀលថ្ងៃចន្ទ ៨រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥ សមាគមឧកញ៉ាកម្ពុជា បានបើកកិច្ចប្រជុំក្រុមប្រឹក្សាភិបាលពេញអង្គ លើកទី១០ អាណត្តិទី១ ត្រីមាសទី៣ ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានអង្គប្រជុំ ដោយមានវត្តមានចូលរួមពីសំណាក់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ដែលជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមចំនួន ៣៩រូប ដើម្បីពិនិត្យ ពិភាក្សា និងអនុម័ត ទៅលើរបៀបវារៈសំខាន់ៗមួយចំនួនដូចជា៖

១.ការប្រកាសស្វាគមន៍សមាជិកក្រុមប្រឹក្សាភិបាលបំពេញបន្ថែមថ្មីដែលទើបជាប់ឆ្នោតទាំង ៨រូបរួមមាន៖ ឧកញ៉ាបណ្ឌិត លីរិទ្ធ, ឧកញ៉ាវេជ្ជបណ្ឌិត ជា សុខឃាង, អ្នកឧកញ៉ាបណ្ឌិត សំ សុខនឿន, អ្នកឧកញ៉ា សុខ សុភាព, អ្នកឧកញ៉ា ហេង បូរិន, ឧកញ៉ាបណ្ឌិត ត្រាំង លី, ឧកញ៉ា ម៉ៅ បញ្ញពណ៌ និងអ្នកឧកញ៉ា អ៊ឹង លីហេង។ សូមបញ្ជាក់ថា សម្រាប់អាណត្តិទី១នេះ សមាគមឧកញ៉ាកម្ពុជា មានសមាជិកក្រុមប្រឹក្សាភិបាលសរុបចំនួន ៥៣រូប។

២. ការពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ និងស្ថិតិសមាជិកចាប់ពីខែមករាដល់ខែសីហា ឆ្នាំ២០២៥

៣. ការពិនិត្យ និងអនុម័តទៅការប្រើប្រាស់ថវិការបស់ "មូលនិធិពិសេសដើម្បីកងទ័ពកម្ពុជានៅសមរភូមិមុខ"

៤.របៀបវារៈផ្សេងៗទៀតដើម្បីផ្តល់ធាតុចូលក៏ដូចជាមតិយោបល់ល្អៗដែលជាគុណប្រយោជន៍សម្រាប់ការអនុវត្តផែនការសកម្មភាពការងារប្រចាំត្រីមាសទី៤នៃឆ្នាំ២០២៥ឱ្យទទួលបានលទ្ធផលល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាព ក្នុងនោះក៏មានពិភាក្សាអំពីការបន្ធូរបន្ថយភាគទានសមាជិកភាពប្រចាំឆ្នាំ សម្រាប់ឆ្នាំ២០២៦ តទៅផងដែរ។

ដោយសារតែរបៀបវារៈទាំងអស់ត្រូវបានពិភាក្សា ពិនិត្យ អនុម័ត និងឯកភាពរួចរាល់ កិច្ចប្រជុំក៏ត្រូវបានបិទបញ្ចាប់ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។





























# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីដាក់ក្រពុំបិណ្ឌផ្កាឈូកគោរពរដ្ឋធម្មនុញ្ញក្នុងឱកាស ខួបលើកទី៣២ ទិវាប្រកាសរដ្ឋធម្មនុញ្ញ

នាព្រឹកថ្ងៃពុធ ២កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំគណៈប្រតិភូដែលរួមមានសមាសភាពលោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាច្រើនរូបអញ្ជើញដាក់ក្រពុំបិណ្ឌផ្កាឈូកគោរពរដ្ឋធម្មនុញ្ញក្នុងឱកាសខួបលើកទី៣២ ទិវាប្រកាសរដ្ឋធម្មនុញ្ញ (២៤ កញ្ញា ១៩៩៣ - ២៤ កញ្ញា ២០២៥) នៅនីតិបូជនីយដ្ឋានវិមានរដ្ឋធម្មនុញ្ញ នាសួនច្បារខាងលិចវិមានឯករាជ្យ រាជធានីភ្នំពេញ។

សូមបញ្ជាក់ថា នៅថ្ងៃទី២៤ ខែកញ្ញានេះ គឺជាខួបទី៣២ឆ្នាំ ដែលកម្ពុជាបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលផ្តើមចេញពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ស្តីពីដំណោះស្រាយរួមបញ្ចប់នូវវិបត្តិកម្ពុជាជាប្រវត្តិសាស្ត្រដែលបន្ទាប់មកនៅថ្ងៃទី២៣-២៨ ខែឧសភា ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជាលើកដំបូងក្រោមការឧបត្ថម្ភគាំពារពីអង្គការសហប្រជាជាតិ ឬអ៊ុនតាក់ (UNTAC)។ ក្រោយពីការបោះឆ្នោតរួចមក រដ្ឋធម្មនុញ្ញជាតិ ក៏ត្រូវបានបង្កើតឡើងជាប្រវត្តិសាស្ត្រនៅក្នុងឆ្នាំ ១៩៩៣ ផងដែរ។

បន្ទាប់មក នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ អតីតមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ ព្រះអង្គបានឡាយព្រះហត្ថលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាជាផ្លូវការដោយច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របទៅនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។ រដ្ឋធម្មនុញ្ញកម្ពុជា បានចែងអំពីគោលការណ៍នៃការបែងចែកអំណាចដាច់ដោយឡែកពីគ្នាគឺ អំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ហើយក៏បានអនុម័តនូវសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ និងគោលការណ៍នីតិរដ្ឋជាដើម។

















# អ្នកឧកញ៉ា ហ៊ី បារី សមាជិកក្រុមប្រឹក្សាភិបាល ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួម «វេទិកាជំនួបរវាងក្រុមការងារជំរុញការវិនិយោគក្នុងភូមិភាគឦសាន និងវិនិយោគិន»

នាថ្ងៃចន្ទ ៧កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០២៥ អ្នកឧកញ៉ា ហ៊ី បារី សមាជិកក្រុម ប្រឹក្សាភិបាល និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុង "វេទិកាជំនួបរវាងក្រុមការងារជំរុញការវិនិយោគក្នុងភូមិភាគឦសាន និងវិនិយោគិន" ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប ទីប្រឹក្សា សម្តេចធិបតីនាយករដ្ឋមន្ត្រី, រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន ក.វ.ឦសាន ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំរបស់ក្រសួង-ស្ថាប័ន និងរដ្ឋបាលខេត្តក្រចេះ, ស្ទឹងត្រែង, មណ្ឌលគិរី, និង រតនគិរី ព្រមទាំងមន្ទីរពាក់ព័ន្ធ ក៏ដូចជាវិនិយោគិនជាតិ និងអន្តរជាតិជាច្រើនរូប។

វេទិកាជំនួបនេះ ត្រូវបានរៀបចំក្នុងគោលបំណង ៖ (១) បន្តផ្សព្វផ្សាយអំពី "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន ឆ្នាំ ២០២៥-២០២៨" (២) ស្វែងយល់អំពីកាលានុវត្តភាពនៃការវិនិយោគក្នុងភូមិភាគឦសាន តាមរយៈ បទបង្ហាញអំពីសកម្មភាពវិនិយោគរបស់ក្រុមហ៊ុនកំពុងវិនិយោគស្រាប់និង (៣) ពិគ្រោះយោបល់ដោយផ្ទាល់ រវាងវិនិយោគិន និង ក.វ.ឦសាន និង តំណាងរដ្ឋបាលខេត្តទាំងបួននៃភូមិភាគឦសាន អំពីបញ្ហាប្រឈម និងដំណោះស្រាយសម្រាប់ការវិនិយោគ។

ក្នុងបរិការណ៍នៃភាពតានតឹងនៅតាមព្រំដែនកម្ពុជា-ថៃ ប្រជាជនកម្ពុជាបានធ្វើពហិការចំពោះទំនិញថៃ និងងាកមកគាំទ្រប្រើប្រាស់ផលិតផលក្នុងស្រុកយ៉ាងផុសផុលដែលឆន្ទៈគាំទ្រផលិតផលក្នុងស្រុករបស់ប្រជាជនកម្ពុជា បានធ្វើឱ្យកម្មវិធីពិសេសជំរុញការវិនិយោគក្នុងភូមិភាគឦសាន បាននិងកំពុងទទួលបានការចាប់អារម្មណ៍កាន់តែច្រើនថែមទៀតពីសំណាក់វិនិយោគិន និងធុរជនតាមរយៈការលើកទឹកចិត្តពិសេសផ្សេងៗសម្រាប់ការវិនិយោគគួបផ្សំនឹងការដោះស្រាយបញ្ហាប្រឈមនានារបស់វិនិយោគិន ការបំពេញបន្ថែមពីគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលក៏ដូចជាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាយុទ្ធសាស្ត្រសំខាន់ៗ រួមទាំងការកសាងផ្លូវក្រវាត់ព្រំដែន ព្រែកជីកហ្វូណនតេជោ កំពង់ផែពហុបំណង និងព្រលានយន្តហោះជាដើមដែលនឹងជួយដល់កម្មវិធីពិពិធកម្មផលិតផល ពង្រឹងភាពតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត និង ប្រព័ន្ធឡូជីស្ទិកដើម្បីគាំទ្រដល់បរិយាកាសវិនិយោគទាំងមូលនៅកម្ពុជា។









# បេសកកម្ម

១ តំណាង និងការពារផលប្រយោជន៍ក៏ដូចជាកត្តយសរបស់សមាជិក

២ កសាងទំនាក់ទំនងប្រកបដោយមិត្តភាព សាមគ្គភាព
សហប្រតបត្តការ ក្នុងមហាគ្រួសារឧកញ៉ា

៣ ជួយគ្នាទៅវញទៅមក ផ្លាស់ប្តូរព័ត៌មាន និងការពិគ្រោះយោបល់

៤ បង្កើនកត្យានុភាព ឧត្តមភាព និងគុណធម៌របស់ឧកញ៉ា
ឱ្យកាន់តែរីកចម្រើននិងរុងរឿងនាពេលអនាគតដោយផ្សារភ្ជាប់ការ
ចូលរួមក្នុងសកម្មភាពសង្គម និងមនុស្សធម៌នានា

៥ លើកកម្ពស់ការគោរពច្បាប់ និងលិខិតបទដ្ឋានគតយុត្តនានា
ក្នុងព្រះរាជាណាចក្រកម្ពុជា

៦ ជំរុញផ្សព្វផ្សាយសក្តានុពល និងកាលានុវត្តភាពនៃការវនិយោគ
ក្នុងព្រះរាជាណាចក្រកម្ពុជា

៧ បង្កើតវេទិកា សិក្ខាសាលា និងកម្មវធីផ្សេងៗពាក់ព័ន្ធនឹងធុរកច្ច
ពាណិជ្ជកម្ម ការវនិយោគ និងវស័យដទៃដើម្បីជាគុណប្រយោជន៍
សម្រាប់សង្គមនិងសេដ្ឋកច្ចជាត

## ទំនាក់ទំនងនិងទទួលបាព័ត៌មានអំពីយើងខ្ញុំតាមរយៈ

Telegram | Facebook | TikTok | Website | Youtube | X(Twitter)

ទីស្នាក់ការ សណ្ឋាគារភ្នំពេញ លេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

(+៨៥៥) ២៣ ៨៦០ ៩៩៩ info@cambodianoknha.org www.cambodianoknha.org